ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(គ.ជ.អ.ប.)

# ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧

ខែមករា ឆ្នាំ២០១៧

# អារម្ភកថា

ចក្ខុវិស័យនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺ**ការបង្វិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាឱ្យទៅកៀកជិតនឹងប្រជាពលរដ្ឋ។** ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ចាំបាច់ត្រូវធ្វើវិមជ្ឈការនូវការផ្តល់សេវាចាំបាច់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានធនធានហិរញ្ញវត្ថុជាឆន្ទានុសិទ្ធិសមស្រប និងធនធានមនុស្សគ្រប់គ្រាន់ ព្រមទាំងសិទ្ធិអំណាចក្នុងការគ្រប់គ្រង ចាត់ចែងធនធានទាំងនោះ។ យន្តការនានាត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារប្រកបដោយតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងចំពោះក្រសួង ស្ថាប័ន ឆ្លើយតបតាមស្តង់ដារនៃការគ្រប់គ្រង និងការផ្តល់សេវានានា។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានសមត្ថភាពក្នុងការអនុវត្តការងារស្របតាមបែបផែនដែលមានការផ្លាស់ប្តូរទាំងនេះ រួមបញ្ចូលទាំងការផ្តួចផ្តើមគំនិតក្នុងការដោះស្រាយនូវបញ្ហានានានៅមូលដ្ឋានរបស់ខ្លួនផងដែរ។

ក្នុងឆ្នាំ២០១៦ យើងបានសម្រេចសមិទ្ធផលជាច្រើនធៀបនឹងចក្ខុវិស័យនេះខាងលើ យើងបានសម្របសម្រួលឱ្យមានការវាយតម្លៃពាក់កណ្តាលកម្មវិធីនៃកម្មវិធីជាតិ ដែលមានលក្ខណៈឯករាជ្យមួយដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពសំខាន់ៗដែលសម្រេចបាននាពេលកន្លងមក ពិសេស តាមរយៈការអនុវត្តផអ៣ទី២។ ជាមួយគ្នានេះដែរ យើងក៏បាននិងកំពុងរៀបចំសេចក្តីព្រាងកម្មវិធីគាំទ្រដែលផ្តល់ហិរញ្ញប្បទានដោយសហភាពអឺរ៉ុប និងបានចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមថ្នាក់ដឹកនាំ មន្ត្រីរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋអំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តាមរយៈការវាយតម្លៃ និងការពិនិត្យមើលឡើងវិញអំពីការអនុវត្តនាពេលថ្មីៗនេះ បានបង្ហាញថាការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមកំពុងតែមានវឌ្ឍនភាព និងបោះជំហានក្នុងគន្លងប្រកបដោយភាពច្បាស់លាស់មួយ។ ជាក់ស្តែង កិច្ចសហការរវាងស្ថាប័នសាធារណៈ និងអង្គការសង្គមស៊ីវិលនានាក្នុងការអនុវត្តកិច្ចការនេះកំពុងមានភាពយ៉ាងល្អប្រសើរ។ យើងក៏កំពុងពិនិត្យ និងកែសម្រួលយន្តការ និងកិច្ចដំណើរការស្តីពីការសម្រុះសម្រួលដោះស្រាយបណ្តឹង ដើម្បីធានាថា ប្រជាពលរដ្ឋមានលទ្ធភាពប្រើប្រាស់យន្តការនេះកាន់តែច្រើនឡើង។ ជាមួយគ្នានេះដែរ រដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅចំនួន៤៧ កំពុងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលគាំទ្រដោយកម្មវិធី ដើម្បីក្រុមប្រឹក្សាមានព័ត៌មានជាមូលដ្ឋានគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងការជជែកពិភាក្សាក្នុងកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចចិត្តនានា។

ពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្ស ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៦ សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពជាច្រើន (ភាគច្រើនជាការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការ) ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ហើយយើងក៏កំពុងដំណើរការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋានផងដែរ។

គួរកត់សម្គាល់ថា ការលើកកម្ពស់គុណភាពនៃការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជា

គោលដៅចម្បងនៃកម្មវិធីជាតិ។ ពាក់ព័ន្ធនឹងកិច្ចការនេះ រួមមានក្រសួង ស្ថាប័នចំនួន១៤ ដែលបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក្នុងឆ្នាំ២០១៧ ក្រសួង ស្ថាប័នទាំងនេះ នឹងទទួលបាននូវការបន្តគាំទ្រពី គ.ជ.អ.ប. ដើម្បីចាប់ផ្តើមផ្ទេរមុខងារជាក់លាក់ជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៧តទៅ។ យើងក៏បានរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំជាច្រើនស្តីពីការអនុវត្តមុខងារជាជម្រើស ឬហៅថាមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការពង្រឹងការផ្តល់សេវារដ្ឋបាលចាំបាច់នានា តាមរយៈការិយាល័យច្រកចេញចូលតែមួយ។

ចំពោះការងារវិមជ្ឈការហិរញ្ញវត្ថុ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត ដែលមានទឹកប្រាក់សរុបចំនួន២០លានដុល្លារ។ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានសហការ និងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធក្នុងការបង្កើនធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេស សមាសភាគផ្នែកអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងឆ្លើយតបចំពោះតម្រូវការនានារបស់ប្រជាពលរដ្ឋដែលមានការកើនឡើងជារៀងរាល់ឆ្នាំ។

ទោះបីយើងមានវឌ្ឍនភាពជាច្រើនគួរជាទីមោទនៈដូចរៀបរាប់ខាងលើក៏ដោយ ប៉ុន្តែ យើងនៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលនៅសេសសល់ និងត្រូវដោះស្រាយក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំចុងក្រោយនៃផអ៣ទី២ក្នុងនោះរួមមាន ៖

**ទីមួយ ៖** រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុកចាំបាច់ត្រូវមានមូលនិឆន្ទានុសិទ្ធិក្នុងចំនួនសមស្របក្នុងការដោះស្រាយបញ្ហានានា និងឆ្លើយតបចំពោះតម្រូវកានៃការផ្តល់សេវាប្រជាពលរដ្ឋ។ ក្នុងន័យនេះ រដ្ឋបាលក្រុង ស្រុកត្រូវមានព័ត៌មានច្បាស់លាស់ និងអាចព្យាករណ៍បានអំពីមូលនិធិរបស់ខ្លួន ពោលគឺរៀងរាល់ឆ្នាំ រដ្ឋបាលក្រុង ស្រុកត្រូវដឹងអំពីចំនួនមូលនិធិដែលទទួលបានតាមរយៈមូលនិធិក្រុង ស្រុក តាមរយៈប្រភពចំណូលផ្ទាល់ពីចំណូលចែករំលែក និងតាមរយៈមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ។ ក្រៅពីនេះ ក្រុង ស្រុកក៏ត្រូវការផងដែរនូវភាពបត់បែន និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចាត់តែងមូលនិធិរបស់ខ្លួន ដែលសមស្របនឹងបទដ្ឋាន និងនីតិវិធីដែលបានកំណត់ និងផ្អែកលើបញ្ហាជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ។

**ទីពីរ ៖** យើងចាំបាច់ត្រូវផ្ទេរនូវការទទួលខុសត្រូវក្នុងការអនុវត្តនូវមុខងាសមស្រប និងចាំបាច់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួង ស្ថាប័នមួយចំនួនពុំទាន់បានកំណត់ច្បាស់លាស់អំពីមុខងារ ដែលត្រូវផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិនៅឡើយទេ។ ដោយឡែក ក្រសួង ស្ថាប័នមួយចំនួនទៀតបានឯកភាព និងសម្រេចចិត្តក្នុងការផ្ទេរមុខងារជាក់លាក់មួយចំនួន ប៉ុន្តែពុំទាន់បានអនុវត្តពេញលេញនូវសេចក្តីសម្រេចនេះនៅឡើយទេ ជាពិសេស ពាក់ព័ន្ធនឹងការផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្ស។ ក្រសួង ស្ថាប័នភាគច្រើនពុំទាន់បានរៀបចំកំណត់ពីស្តង់ដារ ឬសេចក្តីណែនាំបច្ចេកទេសនៃការផ្តល់សេវា និងផ្តល់ការគាំទ្រផ្សេងទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ ស្ថានភាពខាងលើនេះកំពុងក្លាយជាបញ្ហានៅក្នុងការអនុវត្តនូវមុខងារមួយចំនួន ដែលបានផ្ទេរ និងកំពុងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលយើងចាំបាច់ត្រូវរួមគ្នាសិក្សាដោះស្រាយ និងកែលម្អបញ្ហានេះជាបន្ទាន់។

**ទីបី ៖** នៅពេលដែលមុខងារត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ននៅតែមានការទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារបច្ចេកទេសនានា

និងផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្រប។ នេះគឺជាការផ្លាស់ប្តូរមួយដ៏សំខាន់នូវបែបផែននៃការបំពេញការងារដែលក្រសួង ស្ថាប័នធ្លាប់អនុវត្តកន្លងមក។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័នក៏មានកាតព្វកិច្ចក្នុងការធ្វើអធិការកិច្ចលើការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារដែលបានផ្ទេរ និងធនធាននានា ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងស្តង់ដារនានា។ ជាទូទៅ ការធ្វើអធិការកិច្ចមានគោលបំណងលើកកម្ពស់តួនាទី ភារកិច្ច និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការលើកកម្ពស់អភិបាលកិច្ចល្អ ការធានាដល់ការប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវធនធានសាធារណៈ។ អាស្រ័យហេតុនេះ យើងចាំបាច់ត្រូវរៀបចំ និងពង្រឹងកិច្ចដំណើរការក្នុងបែបផែនជាប្រព័ន្ធ និងមានភាពច្បាស់លាស់មួយជាបន្ទាន់។

នៅក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ. ឆ្នាំ២០១៧ ខ្ញុំក៏បានលើកឡើងពីបញ្ហាប្រឈមមួយចំនួនផ្សេងទៀត ដែលយើងបានជួបប្រទះក្នុងឆ្នាំ២០១៦ក្នុងនោះរួមមាន ការពង្រឹងនូវការបញ្ជ្រាបយេនឌ័រ ការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គម ការពង្រឹងវិធីសាស្ត្រសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ការផ្តល់សេវា និងគុណតម្លៃថវិកានៃការអភិវឌ្ឍសមត្ថភាពជាដើម ដែលបញ្ហាទាំងនេះត្រូវបានកំណត់ជាចំណុចដៅជាអាទិភាពសម្រាប់បន្តដោះស្រាយក្នុងឆ្នាំ២០១៧។

ភាពជោគជ័យក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៧ អាស្រ័យលើកិច្ចខិតខំប្រឹងប្រែង ការប្រឹក្សាយោបល់ និងការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតទាំងអស់។ ជាមួយគ្នានេះដែរ ភាពជោគជ័យនៃការអនុវត្តផែនការនេះក៏អាស្រ័យទៅលើការសម្របសម្រួល និងកិច្ចសហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងកម្មវិធីកំណែទម្រង់ផ្សេងទៀតដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកំណែទម្រង់តាមវិស័យនានាផងដែរ។ កំណែទម្រង់ទាំងនេះ គឺជាកត្តាដ៏មានសារសំខាន់ ដើម្បីទទួលបានជោគជ័យក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងនាមរាជរដ្ឋាភិបាល គ.ជ.អ.ប. នឹងបន្តពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ដ៏មានសារសំខាន់ ក្នុងគោលបំណងផ្តល់ជាផលប្រយោជន៍យ៉ាងពិតប្រាកដជូនប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះនានា។

ឯកសារ ផ.ស.ថ. ឆ្នាំ២០១៧ នេះត្រូវបានអនុម័តក្នុងកិច្ចប្រជុំលើកទី១៣របស់ គ.ជ.អ.ប. កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មករា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


អារម្ភកថា ............ i

បញ្ជីរូបភាព ............ v

បញ្ជីតារាង ............ v

បញ្ជីអក្សរកាត់ ............ vi

វាក្យស័ព្ទ និងនិយមន័យ ............ viii

I. សេចក្តីផ្តើម ............ ១

ក. លទ្ធផលរំពឹងទុកឆ្នាំ២០១៧ ............ ៣

ខ. ចំណុចដៅជាអាទិភាពឆ្នាំ២០១៧ ............ ៦

គ. ថវិកានៃ ផ.ស.ថ ឆ្នាំ២០១៧ ............ ៩

គ.១. ផែនការចំណាយ ............ ៩

គ.២. ជំនួយបច្ចេកទេស ............ ១០

គ.៣. ថវិការាជរដ្ឋាភិបាល ............ ១១

គ.៤. សេចក្តីសង្ខេប ............ ១២

II. សមិទ្ធផលរំពឹងទុកនានានៃ ផ.ស.ថ ឆ្នាំ២០១៧ ............ ១៤

១. សមិទ្ធផលរំពឹងទុកទីមួយ ÷ ការគ្រប់គ្រងការងារកំណែទម្រង់ ............ ១៥

១.១. សេចក្តីផ្តើម និងចំណុចដៅ ............ ១៥

១.២. លទ្ធផលរំពឹងទុក និងថវិកា ............ ១៦

២. សមិទ្ធផលរំពឹងទុកទីពីរ ÷ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ............ ២១

២.១. សេចក្តីផ្តើម និងចំណុចដៅ ............ ២១

២.២. លទ្ធផលរំពឹងទុក និងថវិកា ............ ២២

៣. សមិទ្ធផលរំពឹងទុកទីបី ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ............ ២៦

៣.១. សេចក្តីផ្តើម និងចំណុចដៅ ............ ២៦

៣.២. លទ្ធផលរំពឹងទុក និងថវិកា ............ ២៧

៤. សមិទ្ធផលរំពឹងទុកទីបួន ÷ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ............ ៣០

៤.១. សេចក្តីផ្តើម និងចំណុចដៅ ............ ៣០

៤.២. លទ្ធផលរំពឹងទុក និងថវិកា ............ ៣១

៥. សមិទ្ធផលរំពឹងទុកទីប្រាំ ÷ វិមជ្ឈការហិរញ្ញវត្ថុ ............ ៣៦

៥.១. សេចក្តីផ្តើម និងចំណុចដៅ ............ ៣៦

៥.២. លទ្ធផលរំពឹងទុក និងថវិកា ............ ៣៧

# បញ្ជីរូបភាព


រូបភាពទី១ ៖ លំដាប់ថ្នាក់នៃលទ្ធផល ........................................ ២
រូបភាពទី២ ៖ និន្នាការជំនួយបច្ចេកទេស និងទិន្នន័យពាក់ព័ន្ធ ........................................ ១០
រូបភាពទី៣ ៖ និន្នាការមូលនិធិឃុំ សង្កាត់ ........................................ ១១
រូបភាពទី៤ ៖ និន្នាការមូលនិធិក្រុង ស្រុក ........................................ ១២
រូបភាពទី៥ ៖ និន្នាការថវិការាជធានី ខេត្ត ........................................ ១២


# បញ្ជីតារាង


តារាងទី១ ៖ លទ្ធផលរំពឹងទុកឆ្នាំ២០១៧ ........................................ ៣
តារាងទី២ ៖ ចំណុចដៅជាអាទិភាពឆ្នាំ២០១៧ ........................................ ៦
តារាងទី៣ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៧ ........................................ ៩
តារាងទី៤ ៖ ព័ត៌មានលម្អិតអំពីមូលនិធិតាមប្រភព ........................................ ១៣
តារាងទី៥ ៖ ចំណុចដៅនានារបស់សមិទ្ធផលរំពឹងទុកទី១ ........................................ ១៥
តារាងទី៦ ៖ ចំណុចដៅនានារបស់សមិទ្ធផលរំពឹងទុកទី២ ........................................ ២១
តារាងទី៧ ៖ ចំណុចដៅនានារបស់សមិទ្ធផលរំពឹងទុកទី៣ ........................................ ២៦
តារាងទី៨ ៖ ចំណុចដៅនានារបស់សមិទ្ធផលរំពឹងទុកទី៤ ........................................ ៣០
តារាងទី៩ ៖ ចំណុចដៅនានារបស់សមិទ្ធផលរំពឹងទុកទី៥ ........................................ ៣៦

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផអ៣ទី១ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី១ (២០១១-២០១៤) នៃកម្មវិធីជាតិ |
| ផអ៣ទី២ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) នៃកម្មវិធីជាតិ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| Basket | មូលនិធិកញ្ចប់រួមគាំទ្រដោយ Sida, SDC និង EU |
| I4C | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ការអនុវត្តផែនការគណនេយ្យភាពសង្គម |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| EU | សហភាពអឺរ៉ុប |
| GIZ/RED III | គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ដំណាក់កាលទី៣ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/PPTA | គម្រោងជំនួយបច្ចេកទេសសម្រាប់ការរៀបចំកម្មវិធី គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/DPFSM | កម្មវិធីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈបែបវិមជ្ឈការ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/TS-PRSDP | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី |
| ADB/CDRR | គម្រោងគ្រប់គ្រងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន |
| ADB/SPCR | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ |
| IFAD/ASPIRE | គម្រោងសេវាកសិកម្មសម្រាប់ការផ្តួចផ្តើម ភាពធន និងការផ្សព្វផ្សាយ គាំទ្រដោយមូលនិធិអន្តរជាតិសម្រាប់កិច្ចអភិវឌ្ឍកសិកម្ម |
| SDC | ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍របស់ប្រទេសស្វីស |
| UNCDF | មូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNCDF/LGCCII | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រដោយមូលនិធិសម្រាប់អភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNICEF/ Seth Koma | កម្មវិធីសិទ្ធិកុមារនៃមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNDP-EU/ACES | គម្រោងលើកកម្ពស់សេវារបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រដោយយូអិនឌីភី និងសហភាពអឺរ៉ុប |
| UNFPA | មូលនិធិប្រជាពលរដ្ឋរបស់អង្គការសហប្រជាជាតិ |

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| WB | ធនាគារពិភពលោក |
| WB/LASED II | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជំហានទី២ |
| WFP | អង្គការស្បៀងអាហារពិភពលោក |
| GiZ/DAR | កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ |
| USAID | ទីភ្នាក់ងារសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក |
| RACHA | អង្គការសម្ព័ន្ធភាពកុមារ និងសុខភាពបន្តពូជ |
| Sida/PACT | អង្គការ **ផេក** កម្ពុជា (អង្គការពង្រឹងសមត្ថភាពផ្នែកអភិបាលកិច្ច) |
| PAF | បញ្ជីលទ្ធផលរំពឹងទុក និងសូចនាករនៃក្របខ័ណ្ឌការវាយតម្លៃកម្មវិធី |

# វាក្យស័ព្ទ និងនិយមន័យសំខាន់ៗ

| | |
|---|---|
| គណនេយ្យភាព | កាតព្វកិច្ចនៃអ្នកអនុវត្តសិទ្ធិអំណាចក្នុងការឆ្លើយបំភ្លឺអំពីសកម្មភាពនានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលអាចដាក់នូវការពិន័យទោសក្នុងករណីខកខានមិនបានអនុវត្ត។ |
| ការគ្រប់គ្រងផ្អែកលើលទ្ធផល | វិធីសាស្ត្រវិលជុំសម្រាប់ការគ្រប់គ្រងដែលធ្វើសមាហរណកម្មនៃយុទ្ធសាស្ត្រ មនុស្ស ធនធាន កិច្ចដំណើរការ និងវិធានការនានា ដើម្បីលើកកម្ពស់ការសម្រេចចិត្ត តម្លាភាព និងគណនេយ្យភាព។ វិធីសាស្ត្រនេះផ្តោតលើការសម្រេចបាននូវសមិទ្ធផល ការអនុវត្ត នូវការវាស់វែងនៃការអនុវត្តការងារ ការសិក្សារៀនសូត្រ និងការសម្របសម្រួល ក៏ដូចជា ការរៀបចំរបាយការណ៍យ៉ាងច្បាស់លាស់។ |
| តម្លាភាព | ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ហើយព័ត៌មាននេះអាចទទួលបានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់។ |
| ការអភិវឌ្ឍសមត្ថភាព | ជាដំណើរការមួយដែលនាំមកនូវការលើកកម្ពស់ជំនាញ (ទាំងជំនាញទូទៅ និងជំនាញជាក់លាក់) ដែលធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងការពង្រឹងស្ថាប័ន។ ការកសាងសមត្ថភាពសំដៅលើការវិនិយោគលើមនុស្ស ស្ថាប័ន និងបែបផែននៃការអនុវត្តនានា។ |
| ការចូលរួមរបស់សង្គមស៊ីវិល | ជាដំណើរការនៅក្នុងសហគមន៍ដែលប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបង្កើតឡើងដើម្បីសម្រេចគោលដៅរួមនានារបស់ខ្លួននៅមូលដ្ឋាន និងធ្វើការងារជាបុគ្គល ឬរួមគ្នាតាមរយៈអង្គការសហគមន៍មិនមែនរដ្ឋាភិបាលដើម្បីមានឥទ្ធិពលទៅលើដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ |
| អង្គការសហគមន៍ ឬអង្គការសង្គមស៊ីវិល | ជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញដែលមានវត្តមានក្នុងសង្គមដែលតំណាងឱ្យផលប្រយោជន៍ និងគុណតម្លៃរបស់សមាជិកខ្លួន ឬអ្នកដទៃ ដោយផ្អែកលើការយកចិត្តទុកដាក់នានាដែលមានលក្ខណៈជាក្រមសីលធម៌ វប្បធម៌ នយោបាយ វិទ្យាសាស្ត្រ សាសនា ឬសប្បុរសធម៌។ |
| ការវាយតម្លៃ | ជាការវិនិច្ឆ័យទៅលើគុណតម្លៃ ផលប្រយោជន៍ និងតម្លៃនៃការងារអ្វីមួយ ជាការសិក្សាវាយតម្លៃអំពីភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព ផលប៉ះពាល់ និរន្តរភាព និងភាពពាក់ព័ន្ធនៃគម្រោងមួយ ស្របតាមគោលបំណងនានាដែលបានកំណត់។ |
| អភិបាលកិច្ច | ជាប្រពៃណី និងការរៀបចំនូវស្ថាប័ននានាដែលអាជ្ញាធរនៃប្រទេសមួយបានប្រើប្រាស់។ ជាមធ្យោបាយនៃការអនុវត្តសិទ្ធិអំណាចដែលជះឥទ្ធិពលទៅលើជីវភាពសាធារណៈ ជាពិសេស ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ |
| ផលប៉ះពាល់ | ការជះឥទ្ធិពលជាវិជ្ជមាន និងជាអវិជ្ជមានចំពោះមុខ និងយូរអង្វែង ដែលផ្តើមចេញពីកិច្ចអន្តរាគមន៍នៃការអភិវឌ្ឍមួយមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។ |

| | |
|---|---|
| សូចនាករ | កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់ជាមធ្យោបាយមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាដែលកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។ |
| ធាតុចូល | ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ ឯកសារ របាយការណ៍នានា ដែលបានប្រើប្រាស់សម្រាប់កិច្ចអន្តរាគមន៍ដល់ការអភិវឌ្ឍនានា។ |
| លទ្ធផលជាគន្លឹះ | ជាសកម្មភាពសំខាន់ ឬជាគន្លឹះដែលបានកំណត់ ឬដៅទុកសម្រាប់ការត្រួតពិនិត្យ ជាពិសេសពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការសម្រេចបាន។ |
| ការត្រួតពិនិត្យ | ជាការប្រមូល ការវិភាគ និងការប្រើប្រាស់មានលក្ខណៈជាប្រព័ន្ធ និងជាប្រចាំនូវព័ត៌មាននានាក្នុងគោលបំណងត្រួតពិនិត្យការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត។ |
| សមិទ្ធផលរំពឹងទុក | ជាការផ្លាស់ប្តូរ ឬការធ្វើឱ្យប្រសើរឡើងដោយផ្ទាល់នូវសុខមាលភាពនៃអ្នកទទួលផល ឬអតិថិជន ដែលជាលទ្ធផលនៃការប្រើប្រាស់សេវាមួយ (ឬលទ្ធផលរំពឹងទុក)។ |
| លទ្ធផលរំពឹងទុក | ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានាផ្តើមចេញពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុកនានា។ ស្ថាប័ននានាត្រូវមានគណនេយ្យភាពក្នុងការសម្រេចលទ្ធផលរំពឹងទុកឱ្យបានទាន់ពេលវេលា មានគុណភាព និងបរិមាណសមស្រប។ |
| សកម្មភាព | ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជាមូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានកៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។ |
| គោលនយោបាយ (គោលនយោបាយសាធារណៈមួយ) | សកម្មភាព គោលការណ៍ ឬសំណុំនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានគោលបំណង និងភាពស៊ីសង្វាក់គ្នាមួយ ដើម្បី (១)រៀបចំឆ្លើយតបនឹងបញ្ហាមួយ (២)រៀបចំដោយកិច្ចដំណើរការនយោបាយជាក់លាក់ណាមួយ និង(៣)អនុម័ត អនុវត្ត និងពង្រឹងការអនុវត្តដោយស្ថាប័នមួយ។ |
| កម្មវិធី | ជាអន្តរាគមន៍មួយដែលមានកំណត់ពេលវេលាជាក់លាក់ ដែលមានលក្ខណៈខុសគ្នាពីគម្រោងពីព្រោះជាទូទៅ កម្មវិធីគឺមានលក្ខណៈអន្តរវិស័យ គ្របដណ្តប់លើប្រធានបទផ្សេងៗ និងឬមានតំបន់គោលដៅច្រើន ប្រើប្រាស់វិធីសាស្ត្រចំរុះពាក់ព័ន្ធនឹងស្ថាប័នច្រើនជាងស្ថាប័នអនុវត្តគម្រោង និងអាចគាំទ្រដោយប្រភពទុនផ្សេងៗ។ |
| បរិយាប័ន្ន | ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ គោលបំណងនៃបរិយាប័ន្ន គឺការផ្តល់នូវសិទ្ធិឱ្យក្រុមផ្សេងគ្នាៗ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះទទួលបាននូវឱកាសសមស្រប ព្រមទាំងធានាថាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវភាព |

រស់នៅរបស់ពួកគាត់ ក៏ដូចជាដើម្បីធានាឱ្យពួកគេទទួលបាន និងប្រើប្រាស់ដោយស្មើភាពនូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្ត។

**សមធម៌សង្គម** ការលើកកម្ពស់សិទ្ធិក្នុងការទទួលបាន និងការប្រើប្រាស់ដោយយុត្តិធម៌នូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្តសម្រាប់ការរស់នៅ និងការចូលរួមយ៉ាងពេញលេញក្នុងការងារនយោបាយ និងវប្បធម៌នៅក្នុងសង្គម ក៏ដូចជាសិទ្ធិក្នុងការកំណត់ដោយខ្លួនឯងដើម្បីសម្រេចបាននូវសេចក្តីត្រូវការជាមូលដ្ឋាននានារបស់ខ្លួន។ ក្នុងការងាររដ្ឋបាលសាធារណៈ សមធម៌សង្គមសំដៅលើការគ្រប់គ្រងស្ថាប័ននានាដែលបម្រើផលប្រយោជន៍សាធារណៈ ការផ្តល់សេវាសាធារណៈ និងការរៀបចំ និងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋាននានាប្រកបដោយយុត្តិធម៌ និងសមធម៌។



ឰ

# I. សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានកំណត់នូវចក្ខុវិស័យយ៉ាងច្បាស់លាស់ក្នុងការជំរុញឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន តាមរយៈការកំណត់ឡើងនូវលទ្ធផលរំពឹងទុកចំនួន ២៧ និងយុទ្ធសាស្ត្រចំនួន១០៥ ដែលត្រូវអនុវត្តពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧។ ផែនការអនុវត្តនេះត្រូវបាននិងកំពុងអនុវត្តដោយស្ថាប័នសរុបចំនួន២៤៣ ក្នុងនោះរួមមានក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន ២១ រដ្ឋបាលរាជធានី ខេត្តចំនួន២៥ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១៩៧។ គោលបំណងរបស់ ផអ៣ទី២ គឺលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឲ្យកាន់តែមានប្រសិទ្ធភាព ពិសេសនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ទោះបីកម្មវិធីនេះត្រូវអនុវត្តនៅគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើនេះ ចាំបាច់ត្រូវបង្វិតការធ្វើសេចក្តីសម្រេចចិត្ត ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឱ្យទៅកៀកជិតនឹងប្រជាពលរដ្ឋ ដើម្បីធានានូវការឆ្លើយតប ភាពជាម្ចាស់ ការទទួលខុសត្រូវ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាតំណាងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងប្រែក្លាយរដ្ឋបាលទាំងនោះឲ្យទៅជាអ្នកផ្តល់សេវាដ៏សំខាន់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើភាពជោគជ័យដែលទទួលបានពីការអនុវត្តផែនការអនុវត្តបីឆ្នាំដំណាក់កាលទី១ ការអនុវត្ត ផ.ស.ថ. ឆ្នាំទី១(២០១៥) និងឆ្នាំទី២(២០១៦)នៃផអ៣ទី២ ផ.ស.ថ. ឆ្នាំទី៣(២០១៧)នៃផអ៣ទី២មានគោលបំណង ៖

- ផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនក្នុងការធ្វើសេចក្តីសម្រេចចិត្តឆន្ទានុសិទ្ធិ និងស្វ័យភាព
- ផ្តល់ទំនួលខុសត្រូវកាន់តែច្រើនឡើងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាមូលដ្ឋាននានាដូចជា ការអប់រំជាដើម។ កិច្ចការនេះនឹងត្រូវធ្វើឡើងតាមរយៈការផ្ទេរទំនួលខុសត្រូវក្នុងការផ្តល់សេវាពីក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវាកាន់តែច្រើនឡើង ផ្អែកលើសិទ្ធិក្នុងការផ្តួចផ្តើមនានារបស់រដ្ឋបាលទាំងនោះ
- ផ្តល់សិទ្ធិអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើង ក្នុងការគ្រប់គ្រងធនធាននានារបស់ខ្លួន រួមទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស
- លើកកម្ពស់អភិបាលកិច្ចល្អ ការឆ្លើយតប និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានដូចជា ស្ត្រី បុរស យុវជន ក្រុមជនងាយរងគ្រោះ និងក្រុមជនជាតិដើមភាគតិច

- លើកកម្ពស់ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការសម្របសម្រួលនូវការផ្លាស់ប្តូរនានាដូចបានរៀបរាប់ខាងលើ។

**រូបភាពទី១ ៖ លំដាប់ថ្នាក់នៃលទ្ធផល**




ផ.ស.ថ ឆ្នាំ២០១៧ រៀបរាប់អំពីចំណុចដៅជាអាទិភាព លទ្ធផលរំពឹងទុក និងសកម្មភាពនានា ព្រមទាំងផែនការថវិកាសម្រាប់ការអនុវត្តក្នុងឆ្នាំទី៧នៃកម្មវិធីជាតិ ហើយក៏ជាឆ្នាំចុងក្រោយនៃផអ៣ទី២។

ចំណុចដៅអាទិភាព លទ្ធផលរំពឹងទុក និងសកម្មភាពទាំងនេះត្រូវបានរៀបចំឡើងក្នុងត្រីមាសទី៤ឆ្នាំ២០១៦ តាមរយៈការប្រឹក្សាយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា រួមបញ្ចូលទាំងការរៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ. ឆ្នាំ២០១៧របស់ គ.ជ.អ.ប. ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមជាង៥០០នាក់។

ឯកសារ ផ.ស.ថ. ឆ្នាំ២០១៧ ចែកចេញជាពីរផ្នែក។ ផ្នែកទី I (សេចក្តីផ្តើម) បរិយាយដោយសង្ខេបអំពីចក្ខុវិស័យ និងគោលបំណងនៃផអ៣ទី២ គោលបំណងនៃផ.ស.ថ. ឆ្នាំ២០១៧ ការរៀបរាប់ដោយសង្ខេប[1]អំពីលទ្ធផលរំពឹងទុក និងចំណុចដៅជាអាទិភាពដែលត្រូវសម្រេចឲ្យបានក្នុងឆ្នាំ២០១៧ ព្រមទាំងការបរិយាយអំពីប្រភពមូលនិធិ និងគម្រោងចំណាយរបស់ ផ.ស.ថ.ឆ្នាំ២០១៧។ ផ្នែកទី II រៀបរាប់អំពីលទ្ធផលរំពឹងទុក និងយុទ្ធសាស្រ្តពាក់ព័ន្ធដែលត្រូវសម្រេចក្នុងឆ្នាំ២០១៧ តាមសមិទ្ធផល

[1] ការរៀបរាប់លម្អិតអំពីលទ្ធផលរំពឹងទុកមួយចំនួនមានក្នុងឯកសារផ្សេងដូចជា លទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម ការប្រាស្រ័យទាក់ទង ការផ្តល់សេវាសង្គមមានរៀបរាប់លម្អិតក្នុងផែនការយុទ្ធសាស្រ្តស្តីពីការងារគណនេយ្យភាពសង្គម ឯកសារយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទង ឯកសារ គម្រោងកម្មវិធីសិទ្ធិកុមារ...។

នីមួយៗនៃផអ៣ទី២។ ចំពោះឯកសារពាក់ព័ន្ធមួយចំនួនទៀតដូចជា សកម្មភាពលម្អិត និងថវិកានៃលទ្ធផលរំពឹងទុកទាំងអស់ តារាងចំណាយ ជំនួយបច្ចេកទេស និងសុន្ទរកថាបើក សុន្ទរកថាបិទរបស់ថ្នាក់ដឹកនាំ គ.ជ.អ.ប. ក្នុងឱកាសសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ. ឆ្នាំ២០១៧ មានភ្ជាប់ Online និងអាចទាញយកបាន។

### គ. លទ្ធផលរំពឹងទុកឆ្នាំ២០១៧

ក្នុងឆ្នាំ២០១៧ដែលជាឆ្នាំចុងក្រោយនៃ ផអ៣ទី២ គ.ជ.អ.ប. បានកំណត់លទ្ធផលរំពឹងទុកចំនួន **៣៧**សម្រាប់ការរៀបចំជា ផ.ស.ថ. ឆ្នាំ២០១៧ ដោយផ្អែកជាមូលដ្ឋានលើ ៖

- សមិទ្ធផលទាំង៥ និងលទ្ធផលរំពឹងទុកនានានៃផអ៣ទី២
- លទ្ធផលរំពឹងទុកជាអាទិភាពដែលត្រូវអនុវត្តបន្តពីឆ្នាំ២០១៦ និងត្រូវការរយៈពេលអនុវត្តន៍ច្រើនឆ្នាំដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនេះ។ ភាគច្រើននៃលទ្ធផលរំពឹងទុកទាំងនេះ គឺជាលទ្ធផលរំពឹងទុកដែលត្រូវបន្តពីឆ្នាំ២០១៦។
- ជាលទ្ធផលរំពឹងទុកថ្មីក្នុងផអ៣ទី២ដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៧ ដូចជា ការរៀបចំ ផអ៣ទី៣ ការរៀបចំឯកសារគោលនយោបាយស្តីពីចំណូល និងចំណាយសម្រាប់រយៈពេលវែង និងរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

តារាងខាងក្រោមបរិយាយអំពីលទ្ធផលរំពឹងទុកទាំង**៣៧**នៃ ផ.ស.ថ. ឆ្នាំ២០១៧ ដែលនឹងត្រូវសម្របសម្រួលអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចមានរៀបរាប់ក្នុងផ្នែកទី II។

**តារាងទី១ ៖ លទ្ធផលរំពឹងទុកនៃ ផ.ស.ថ. ឆ្នាំ២០១៧**

| ល.រ. | លទ្ធផលរំពឹងទុក |
|---|---|
| ១ | ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. យ៉ាងហោចចំនួន២លើកក្នុងមួយឆ្នាំ ដើម្បីដឹកនាំ និងសម្របសម្រួលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ២ | ការរៀបចំ និងការអនុម័តផែនការអនុវត្តរយៈពេលបីឆ្នាំ ២០១៨-២០២០ ដំណាក់កាលទី៣នៃកម្មវិធីជាតិ |
| ៣ | ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៤ | ការពង្រឹង និងការអនុវត្តកិច្ចដំណើរការអភិបាលកិច្ច ការកសាងផែនការ និងការត្រួតពិនិត្យ និងវាយតម្លៃនៃផអ៣ |
| ៥ | ការពង្រឹង និងការអនុវត្តនីតិវិធីគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប. |
| ៦ | ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ៧ | ការពង្រឹងការសម្របសម្រួល និងការប្រឹក្សាយោបល់ជាប្រចាំរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងកម្មវិធីកំណែទម្រង់នានាអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |



ល

| ល.រ. | លទ្ធផលរំពឹងទុក |
|---|---|
| ៨ | ការពិនិត្យឡើងវិញ និងការសម្រួលរចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ |
| ៩ | ការពិនិត្យ និងកែសម្រួលនូវប្រព័ន្ធ និងនីតិវិធីនានានៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ខ្សែគណនេយ្យភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១០ | ការអនុវត្តផែនការស្តីពីការងារគណនេយ្យភាពសង្គមក្នុងស្រុកគោលដៅចំនួន៩០ស្រុក |
| ១១ | ការរៀបចំ និងការដាក់ឱ្យអនុវត្តយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១២ | ការរៀបចំ និងអនុម័តឯកសារគោលនយោបាយ/ឯកសារទស្សនទាន/ផែនការយុទ្ធសាស្ត្រស្តីពីអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា |
| ១៣ | ការពិនិត្យមើលឡើងវិញ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាល ក្រុង ស្រុក ខណ្ឌ |
| ១៤ | ការរៀបចំ ការធ្វើសមាហរណកម្ម និងការអនុវត្តនូវប្រព័ន្ធព័ត៌មានស្តីពីការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយក្រុង ស្រុក ខណ្ឌ |
| ១៥ | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១៦ | ការលើកកម្ពស់ និងការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្ននិងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១៧ | ការលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ស្ថាប័នរាជរដ្ឋាភិបាលដែលមានស្រាប់ និងកិច្ចសហការរវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន |
| ១៨ | ការលើកកម្ពស់សមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ១៩ | ការរៀបចំ និងការអនុម័តផែនការអនុវត្តន៍សម្រាប់ការបង្កើត និងការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ២០ | ការលើកកម្ពស់ការផ្តល់សេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ |
| ២១ | ការផ្ទេរ និងការអនុវត្តការប្រគល់មុខងារពាក់ព័ន្ធនឹងគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដោយរដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តចំនួន១យ៉ាងតិច |
| ២២ | ការរៀបចំ និងការផ្ទេរមុខងារពីក្រសួងចំនួន២ផ្សេងទៀតយ៉ាងតិចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាលជាដើម។ល។ |
| ២៣ | ការរៀបចំរបាយការណ៍ស្តីពីការវិភាគមុខងារនិងការពិនិត្យមើលឡើងវិញនូវមុខងារ និងលិខិតបទដ្ឋាននានាស្តីពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងចំនួន១០ផ្សេងទៀត |

| ល.រ. | លទ្ធផលរំពឹងទុក |
|---|---|
| ២៤ | រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព ដោយសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា |
| ២៥ | ការរៀបចំ និងការផ្ទេរមុខងារនានាស្តីពីការគ្រប់គ្រងសេវាទីប្រជុំជនពីខេត្តទៅឱ្យរដ្ឋបាលក្រុងគោលដៅ |
| ២៦ | ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៥២ |
| ២៧ | ការបង្កើនមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ ដើម្បីជួយរដ្ឋបាលក្រុង ស្រុកមានធនធានសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន |
| ២៨ | ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នាស្តីពីលក្ខខណ្ឌសម្រាប់ការចំណាយមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ |
| ២៩ | ការដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣០ | ការរៀបចំឯកសារគោលនយោបាយស្តីពីចំណូល និងចំណាយសម្រាប់រយៈពេលវែង និងរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣១ | ការបន្តការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣២ | ការរៀបចំបញ្ចប់ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣៣ | ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងតម្លាភាព |
| ៣៤ | ការពិនិត្យមើលឡើងវិញ និងការអនុម័តនូវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃថវិការាជធានី ខេត្ត |
| ៣៥ | ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣៦ | ការផ្សព្វផ្សាយសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមប្រភេទថ្នាក់រដ្ឋបាលនីមួយៗ |
| ៣៧ | ការពង្រឹងការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យមូលដ្ឋាន និងឯកសារពាក់ព័ន្ធ រួមបញ្ចូលទាំងទិន្នន័យអំពីសេវាសង្គម ការប្រែប្រួលអាកាសធាតុ សម្រាប់កិច្ចដំណើរការនៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

## ២. ចំណុចដៅជាអាទិភាពឆ្នាំ២០១៧

ផ្អែកលើលទ្ធផលរំពឹងទុកទាំង៣៧នៃ ផ.ស.ថ. ឆ្នាំ២០១៧ គ.ជ.អ.ប. បានកំណត់ចំណុចដៅជាអាទិភាពចំនួន២២ដែលត្រូវសម្រេចឱ្យបាន។ តារាងខាងក្រោមបរិយាយអំពីចំណុចដៅជាអាទិភាពទាំង ២២ រួមទាំងសកម្មភាព ឬចំណុចដៅដែលត្រូវសម្រេចតាមត្រីមាសនីមួយៗ។

**តារាងទី២៖ ចំណុចដៅជាអាទិភាពក្នុងឆ្នាំ២០១៧**

| ចំណុចដៅជាអាទិភាព | សកម្មភាពដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| 1. កិច្ចប្រជុំ គ.ជ.អ.ប. យ៉ាងតិចចំនួន២ លើកត្រូវបានរៀបចំ ដើម្បីដឹកនាំ និង សម្រប សម្រួលកំណែទម្រង់នៃការ អភិវឌ្ឍតាម បែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ (១.១.២.១) | • យ៉ាងតិច កិច្ចប្រជុំចំនួន១ត្រូវបានរៀបចំ<br>• យ៉ាងតិច កិច្ចប្រជុំសរុបចំនួន២ត្រូវបានរៀបចំ | ទី១<br>ទី៣ |
| 2. ការរៀបចំ និងការអនុម័ត ផអ៣ទី៣ ២០១៨-២០២០នៃកម្មវិធីជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ (១.១.២.២) | • ឯកសារបំពេញបន្ថែមលើកម្មវិធីជាតិត្រូវបានអនុម័ត និង ទីប្រឹក្សារៀបចំផអ៣ទី៣ត្រូវបានជ្រើសរើស<br>• អនុវត្តកិច្ចដំណើរការរៀបចំផអ៣ទី៣<br>• ផអ៣ទី៣ត្រូវបានអនុម័ត | ទី១<br>ទី២<br>ទី៤ |
| 3. ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ច ដំណើរការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. (១.២.១.១) | • រចនាសម្ព័ន្ធ និងតម្រូវការជំនួយបច្ចេកទេសរបស់លេខា ធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល<br>• លេខាធិការដ្ឋានរៀបចំទស្សនកិច្ចសិក្សារួមគ្នាជាមួយដៃគូ អភិវឌ្ឍន៍នានា ដើម្បីតាមដានការអនុវត្តកម្មវិធី | ទី២<br>ទី៤ |
| 4. ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យ ទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (១.៣.២.១) | • បណ្ណុំព័ត៌មាន (រូបថត និងក្រាហ្វិក) មានគុណភាពខ្ពស់ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>• ខិត្តប័ណ្ណចំនួន២បានរៀបចំ ផលិត និងផ្សព្វផ្សាយ<br>• យុទ្ធនាការផ្សព្វផ្សាយស្តីពីការផ្ទេរមុខងារវិស័យអប់រំទៅ ឱ្យរដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ | ទី៣<br>ទី២<br>ទី៣ |
| 5. ការអនុវត្តផែនការស្តីពីការងារគណ នេយ្យភាពសង្គមក្នុងស្រុកគោលដៅ ចំនួន៩០ស្រុក (២.២.១.១) | • យ៉ាងតិច៨០%នៃឃុំក្នុងស្រុកគោលដៅបានបញ្ចូល ព័ត៌មាន I4C ក្នុងប្រព័ន្ធកុំព្យូទ័រ<br>• យ៉ាងតិច៨០%នៃឃុំក្នុងស្រុកគោលដៅបានរៀបចំ JAAP<br>• ការសិក្សាអំពីនិរន្តរភាពអំពី ISAF ត្រូវបានអនុវត្ត និង បង្ហាញដល់អ្នកពាក់ព័ន្ធនានា | ទី២<br>ទី៤<br>ទី៤ |
| 6. ការរៀបចំ និងការដាក់ឱ្យអនុវត្តយន្ត ការសម្រុះសម្រួលដោះស្រាយបណ្តឹង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២.២.៣.១) | • អនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការបង្កើតការិយាល័យ ប្រជាពលរដ្ឋត្រូវបានអនុម័ត<br>• សៀវភៅណែនាំស្តីពីនីតិវិធីសម្រាប់ស្រាវជ្រាវបណ្តឹងត្រូវ បានអនុម័ត<br>• យន្តការសម្រុះសម្រួលដោះស្រាយបណ្តឹង ត្រូវបានពិនិត្យ | ទី១<br>ទី២<br>ទី៤ |

| ចំណុចដៅជាអាទិភាព | សកម្មភាពដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| | និងវាយតម្លៃ | |
| 7. ការរៀបចំ និងអនុម័តឯកសារគោលនយោបាយ/ឯកសារទស្សនទាន/ផែនការយុទ្ធសាស្ត្រស្ដីពីអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា (២.៣.១.១) | • ការពិនិត្យមើលឡើងវិញ និងការវិភាគអំពីជម្រើសនានាត្រូវបានបញ្ចប់<br>• ឯកសារគោលនយោបាយ/ ឯកសារទស្សនទាន/ ផែនការយុទ្ធសាស្ត្រត្រូវបានអនុម័ត | ទី២<br>ទី៤ |
| 8. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំស្ដីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (៣.១.២.១) | • លិខិតបទដ្ឋានគតិយុត្ត សេចក្ដីណែនាំ និងសៀវភៅណែនាំត្រូវបានអនុម័ត<br>• ការផ្សព្វផ្សាយសេចក្ដីណែនាំ និងសៀវភៅណែនាំ តាមរយៈវគ្គបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាព | ទី១<br>ទី៤ |
| 9. ការលើកកម្ពស់ និងការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្ននិងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៣.១.៦.១) | • យុទ្ធសាស្ត្រស្ដីពីការលើកកម្ពស់ស្ត្រីក្នុងមុខតំណែងជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរបាយការណ៍សវនកម្មយេនឌ័រត្រូវបានរៀបចំ<br>• ការលើកកម្ពស់ចំណេះដឹងអំពីយេនឌ័រដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត<br>• ផែនការនៃការជំនួសស្ត្រីក្នុងមុខតំណែងជាអ្នកដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត<br>• បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានបញ្ជ្រាបក្នុងឯកសារបំពេញបន្ថែម និងផអ៣ទី៣ | ទី១<br>ទី៣<br>ទី៤<br>ទី៤ |
| 10. ការលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ស្ថាប័នរដ្ឋាភិបាលដែលមានស្រាប់ និងកិច្ចសហការ រវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា (៣.២.១.១) | • រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងសម្រាប់ថ្នាក់ដឹកនាំក្រុង ស្រុក<br>• លិខិតបទដ្ឋាន និងសេចក្ដីណែនាំស្ដីពីកិច្ចសហការរវាងស្ថាប័នរដ្ឋជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការផ្ដល់សេវាអភិវឌ្ឍន៍សមត្ថភាព | ទី៣<br>ទី៤ |
| 11. ការលើកកម្ពស់សមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ (៣.២.៤.១) | • ផែនការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមប្រឹក្សាភិបាលថ្នាក់ដឹកនាំ និងបុគ្គលិកសមាគមត្រូវបានធ្វើបច្ចុប្បន្នភាព និងអនុវត្ត<br>• យុទ្ធសាស្ត្រស្ដីពីការតស៊ូមតិរបស់សមាគមត្រូវបានរៀបចំ និងអនុវត្ត | ទី៣<br>ទី៤ |
| 12. ការរៀបចំ និងការអនុម័តផែនការអនុវត្តន៍សម្រាប់ការបង្កើត និងការ | • ការវិភាគនានាសម្រាប់ការសិក្សាលទ្ធភាព ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ត្រូវបានបញ្ចប់ | ទី៣ |

| ចំណុចដៅជាអាទិភាព | សកម្មភាពដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| គ្រប់ គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន (៣.៤.៣.១) | • ផែនការសកម្មភាពសម្រាប់បង្កើតសាលាជាតិត្រូវបានអនុម័ត | ទី៤ |
| 13. ការផ្ទេរ និងការអនុវត្តការប្រគល់មុខងារពាក់ព័ន្ធនឹងគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅ ប្រព័ន្ធដោយរដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តចំនួន១យ៉ាងតិច (៤.២.១.១) | • ការអភិវឌ្ឍសមត្ថភាពបុគ្គលិកក្រុង ស្រុក និងឃុំ សង្កាត់ និងការផ្ទេរការិយាល័យអប់រំទៅក្នុងរដ្ឋបាលក្រុង ស្រុកត្រូវបានអនុវត្ត<br>• បុគ្គលិក និងទ្រព្យសម្បត្តិនានាត្រូវបានផ្ទេរ<br>• មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធត្រូវបានវិភាជឱ្យក្រុង ស្រុកសម្រាប់ការរៀបចំថវិកាឆ្នាំ២០១៨ | ទី១<br>ទី២<br>ទី៤ |
| 14. ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៥២ (៤.៤.២.១) | • លិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយត្រូវបានអនុម័ត និងអនុវត្ត<br>• ការិយាល័យ និងយន្តការច្រកចេញចូលតែមួយចំនួន៥៤ ត្រូវបានដាក់ឱ្យដំណើរការ | ទី១<br>ទី៤ |
| 15. ការបង្កើនមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ ដើម្បីជួយក្រុង ស្រុកមានធនធានសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន (៥.១.១.១) | • នឹងត្រូវកំណត់ | |
| 16. ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នាស្តីពីលក្ខខណ្ឌសម្រាប់ការចំណាយមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ (៥.១.៣.១) | • របាយការណ៍ត្រូវបានរៀបចំ ដើម្បីពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានា<br>• ការឯកភាពគ្នា ដើម្បីកែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក | ទី៣<br>ទី៤ |
| 17. ការដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (៥.២.១.១) | • អនុក្រឹត្យស្តីពីការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានអនុម័ត និងអនុវត្ត<br>• មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការផ្ទេរមុខងារ | ទី១<br>ទី៤ |
| 18. ការបន្តការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៥.៤.១.១) | • ឯកសារគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់ត្រូវបានបញ្ចប់<br>• វគ្គបណ្តុះបណ្តាលស្តីពីប្រភពចំណូលផ្ទាល់ ត្រូវបានអនុវត្ត | ទី២<br>ទី៤ |

| ចំណុចដៅជាអាទិភាព | សកម្មភាពដែលត្រូវសម្រេច | ត្រីមាស |
|---|---|---|
| 19. ការរៀបចំបញ្ចប់ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការអនុវត្តគម្រោងគាំទ្រ ដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (៥.៥.១.១) | • សេចក្តីណែនាំ និងសៀវភៅណែនាំនានាត្រូវបានអនុម័ត | ទី១ |
| 20. ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងតម្លាភាព (៥.៥.៦.១) | • លិខិតបទដ្ឋាន និងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងត្រូវបានរៀបចំបញ្ចប់<br>• ការសិក្សាវាយតម្លៃគម្រោងត្រូវបានបញ្ចប់<br>• ការផ្ទេរធនធានគាំទ្រគម្រោងនានា | ទី១<br>ទី៣<br>ទី៤ |
| 21. ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៥.៧.១.១) | • ការសិក្សា ដើម្បីកំណត់ពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការទូទាត់ និងភាពដែលមាននៃមូលនិធិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុត្រូវកែសម្រួល | ទី២<br>ទី៤ |
| 22. ការផ្សព្វផ្សាយ និងការណែនាំសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមប្រភេទថ្នាក់រដ្ឋបាលនីមួយៗ (៥.៨.១.១) | • សេចក្តីណែនាំបច្ចេកទេសទាំងអស់ត្រូវបានអនុម័ត<br>• វគ្គបណ្តុះបណ្តាលអំពីសេចក្តីណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបញ្ចប់ | ទី១<br>ទី៤ |

## គ. ថវិកានៃ ផ.ស.ថ. ឆ្នាំ២០១៧

### គ.១. ផែនការចំណាយ

ផែនការចំណាយនៃថវិកា ផ.ស.ថ ឆ្នាំ២០១៧របស់ គ.ជ.អ.ប. មានសង្ខេបក្នុងតារាងខាងក្រោម ៖

**តារាងទី៣ ៖ ផែនការចំណាយសម្រាប់ឆ្នាំ២០១៧ (គិតជាដុល្លារ)**

| ប្រភេទសកម្មភាព | រាជរដ្ឋាភិបាល | កញ្ចប់រួម និងសហភាពអឺរ៉ុប | គម្រោងនានារបស់ដៃគូ | សរុប | |
|---|---|---|---|---|---|
| **១. ការងារកំណែទម្រង់** | **200,000** | **11,347,966** | **18,588,835** | **30,136,801** | **6.87%** |
| **ក. សកម្មភាព** | **200,000** | **4,698,026** | **18,588,835** | **23,486,861** | **5.36%** |
| សមិទ្ធផលទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់ | 200,000 | 1,049,001 | 0 | **1,249,001** | **0.28%** |
| សមិទ្ធផលទី២ ៖ គណនេយ្យភាពបែបប្រជាធិបតេយ្យ | 0 | 780,960 | 4,034,333 | **4,815,293** | **1.10%** |
| សមិទ្ធផលទី៣ ៖ ការគ្រប់គ្រងធនធានមនុស្ស | 0 | 1,377,197 | 1,577,223 | **2,954,420** | **0.67%** |
| សមិទ្ធផលទី៤ ៖ ការផ្តល់សេវា និងមុខងារ | 0 | 1,021,730 | 11,175,114 | **12,196,844** | **2.78%** |
| សមិទ្ធផលទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ | 0 | 469,138 | 1,802,165 | **2,271,303** | **0.52%** |
| **២ .ចំណាយប្រតិបត្តិការ** | **0** | **2,160,440** | **0** | **2,160,440** | **0.49%** |

| ប្រភេទសកម្មភាព | រាជរដ្ឋាភិបាល | កញ្ចប់រួម និង សហភាពអឺរ៉ុប | គម្រោងនានា របស់ដៃគូ | សរុប | |
|---|---|---|---|---|---|
| គ. ជំនួយបច្ចេកទេស | 0 | 4,489,500 | 0 | 4,489,500 | 1.02% |
| ២. ការផ្ទេរថវិកា (ការផ្តល់សេវា) | 397,196,250 | 2,514,255 | 8,745,796 | 408,456,301 | 93.13% |
| ៣. សរុបរួម (១+២) | 397,396,250 | 13,862,221 | 27,334,631 | 438,593,102 | 100.00% |
| ភាគរយ | 90.49% | 3.10% | 6.41% | 100.00% | |

### គ.២. ជំនួយបច្ចេកទេស

ក្នុងឆ្នាំ២០១៧ មានទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាសរុបចំនួន៦៦០នាក់ ដែលត្រូវការសម្រាប់គាំទ្រការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៧ និងគ្រោងចំណាយថវិកាចំនួនជិត៤,៥លានដុល្លារ។ ទីប្រឹក្សាត្រូវបានជ្រើសរើសក្នុងកម្រិតប្រាក់បៀវត្សមួយ ដែលមានលក្ខណៈប្រកួតប្រជែងជាមួយអង្គការអន្តរជាតិនានា ដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាព និងបំពេញកិច្ចការជាក់លាក់នានាក្នុងបែបផែនប្រហាក់ប្រហែលគ្នានឹងកុងស៊ុលតង់។ បុគ្គលិកកិច្ចសន្យា ត្រូវបានជ្រើសរើសជាបឋមដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានកម្រិតប្រាក់បៀវត្សប្រហាក់ប្រហែលនឹងកម្រិតប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដើម្បីជួយពង្រឹង និងបំពេញសមត្ថភាពមន្ត្រីរាជការដែលនៅខ្វះចន្លោះក្នុងការអនុវត្តកិច្ចការចាំបាច់មួយចំនួន។

ផអ៣ដំណាក់កាលទី២ មានគោលដៅកាត់បន្ថយចំនួនជំនួយបច្ចេកទេស ដើម្បីលើកកម្ពស់និរន្តរភាពកម្មវិធី ការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបង្កើនការវិនិយោគធនធានបន្ថែមទៀតក្នុងការអនុវត្តសកម្មភាពនានា។ រូបភាពទី២ខាងក្រោមនេះ បង្ហាញអំពីកម្រិតចំណាយជំនួយបច្ចេកទេសដែលត្រូវបានកាត់បន្ថយតាមឆ្នាំនីមួយៗឆ្នាំ២០១១ដល់ឆ្នាំ២០១៧។

រូបភាពទី២ ៖ និន្នាការស្តីពីថវិកាជំនួយបច្ចេកទេស និងទិន្នន័យពាក់ព័ន្ធ (គិតជាលានដុល្លារ)




| ឆ្នាំ | កំណែទម្រង់ស្នូល | ជំនួយប/ទជាក់ស្តែង | ចំណុចដៅជំនួយប/ទ | %ថវិកាជំនួយបច្ចេកទេសធៀបនឹងកំណែទម្រង់ស្នូល |
|---|---|---|---|---|
| 2011 | $20.2 | $10.2 | | 50% |
| 2012 | $14.8 | $8.2 | | 55% |
| 2013 | $10.5 | $5.8 | | 55% |
| 2014 | $13.6 | $5.9 | | 43% |
| 2015 | $11.8 | $6.1 | $5.5 | 52% |
| 2016 | $11.2 | $5.0 | $5.0 | 45% |
| 2017 | $11.9 | $4.5 | $4.5 | 38% |

## គ.៣. ថវិកាអភិបាល

ក្នុងឆ្នាំ២០១៧ មូលនិធិឃុំ សង្កាត់នឹងកើនដល់ចំនួន៩២,៧លានដុល្លារអាមេរិក ឬគិតជាមធ្យម មានចំនួន៥៦.៧៦២ដុល្លារអាមេរិកក្នុងមួយឃុំ សង្កាត់នីមួយៗ ដែលក្នុងនោះសមាសភាគអភិវឌ្ឍន៍មាន ចំនួន២២.៣៤៨ដុល្លារ។ មូលនិធិឃុំ សង្កាត់សមាសភាគអភិវឌ្ឍន៍មានចំនួន៣៩,៧%នៃមូលនិធិសរុប។

ចាប់តាំងពីឆ្នាំ២០០២មក មូលនិធិឃុំ សង្កាត់មានការកើនឡើងជាលំដាប់ គឺជាមធ្យមចំនួន ១៨,៩%ក្នុងមួយឆ្នាំ[2]។ ផ្អែកតាមអនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ មូលនិធិឃុំ សង្កាត់ត្រូវបានកំណត់ក្នុងអត្រា២,៨% នៃចំណូលចរន្តថវិកាជាតិ។

ក្នុងឆ្នាំ២០១៧ មូលនិធិក្រុង ស្រុកនឹងកើនដល់ចំនួន៣៣,១លានដុល្លារអាមេរិក ឬគិតជាមធ្យម ចំនួន១៧៨.៩៤៣ដុល្លារសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ។ មួយភាគធំនៃមូលនិធិនេះ (៧១,៤២%) គឺជាចំណាយប្រតិបត្តិការ ជាពិសេសចំណាយបុគ្គលិក។ ជាមធ្យម រដ្ឋបាលក្រុង ស្រុកនីមួយៗទទួល បានមូលនិធិចំនួន៥១.១៣៤ដុល្លារអាមេរិកសម្រាប់សមាសភាគអភិវឌ្ឍន៍។ មូលនិធិក្រុង ស្រុក សមាស ភាគអភិវឌ្ឍន៍មានចំនួន២៨,៥៨%នៃមូលនិធិសរុប។

ចាប់តាំងពីឆ្នាំ២០១៣ មូលនិធិក្រុង ស្រុកមានការកើនឡើងជាលំដាប់ គឺជាមធ្យមចំនួន ២៣,៣%ក្នុងមួយឆ្នាំ[3]។ ផ្អែកតាមអនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក មូលនិធិ ក្រុង ស្រុកត្រូវបានកំណត់ក្នុងអត្រា១,០%នៃចំណូលចរន្តថវិកាជាតិ។

ក្នុងឆ្នាំ២០១៧ ថវិការដ្ឋបាលរាជធានី ខេត្តនឹងកើនដល់ចំនួន២៦៨លានដុល្លារអាមេរិក ឬគិតជា មធ្យម ចំនួន១០,៨លានដុល្លារសម្រាប់រដ្ឋបាលរាជធានី ខេត្តនីមួយៗ។ ជាមធ្យម រាជធានី ខេត្តនីមួយៗ ទទួលបានថវិកាចំនួន៦,៦លានដុល្លារអាមេរិក សម្រាប់កិច្ចអភិវឌ្ឍន៍។ ៨៨%នៃថវិការដ្ឋបាលរាជធានី ខេត្តបានមកពីប្រភពចំណូលផ្ទាល់រួមជាមួយនឹងការផ្ទេរពីថ្នាក់ជាតិចំនួន៣១,៨លានដុល្លារ។

ចាប់តាំងពីឆ្នាំ២០១៣មក ថវិការដ្ឋបាលរាជធានី ខេត្តមានការកើនឡើងជាលំដាប់ គឺជាមធ្យម ចំនួន១៨,៧%ក្នុងមួយឆ្នាំ។ ការផ្ទេរនៃថវិការដ្ឋបាលរាជធានី ខេត្តមានចំនួន០,៩៦%នៃចំណូលចរន្ត ថវិកាជាតិ។

ក្នុងឆ្នាំ២០១៧ មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តមុខងារមួយចំនួនមានចំនួន២,៥លាន ដុល្លារ ដោយមិនគិតបញ្ចូលប្រាក់បៀវត្ស។

**រូបភាពទី៣ ៖ និន្នាការស្តីពីមូលនិធិឃុំ សង្កាត់ (គិតជាលានដុល្លារ)**




---

[2] ការកើនឡើងនូវចំនួនភាគរយ គឺជាតួលេខសរុបដែលបូកយោងពីឆ្នាំមុនៗ។

[3] ការកើនឡើងនូវចំនួនភាគរយ គឺជាតួលេខសរុបដែលបូកយោងពីឆ្នាំមុនៗ។

### រូបភាពទី៤ ៖ និន្នាការស្តីពីមូលនិធិក្រុង ស្រុក (គិតជាលានដុល្លារ)




### រូបភាពទី៥ ៖ និន្នាការស្តីពីថវិការាជធានី ខេត្ត (គិតជាលានដុល្លារ)




## គ.៤. សេចក្តីសង្ខេប

ជារួម ការផ្តល់មូលនិធិគាំទ្រ ផ.ស.ថ. ឆ្នាំ២០១៧ សរុបមានចំនួន៤៣៨,៦លានដុល្លារអាមេរិក ដែលក្នុងនោះ ថវិកាគាំទ្រពីរាជរដ្ឋាភិបាលមានចំនួន៣៩៧,៤លានដុល្លារអាមេរិក ឬស្មើនឹង៩០,៦%។ បន្ថែមលើនេះ តួលេខថវិកាគាំទ្ររបស់រដ្ឋាភិបាលក៏រួមបញ្ចូលនូវកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកដែលមានថវិកាសរុបចំនួន១៦,៦លានដុល្លារអាមេរិក ឬស្មើនឹង៣,៨%។ ព័ត៌មានលម្អិតអំពីថវិកានៃ ផ.ស.ថ. ឆ្នាំ២០១៧ មានបង្ហាញក្នុងតារាងទី៤ទំព័របន្ទាប់។

## តារាងទី៤ ៖ ព័ត៌មានលម្អិតស្ដីពីមូលនិធិតាមប្រភព (គិតជាដុល្លារ)

| ប្រភពផ្ដល់មូលនិធិ | ថវិកាផ្ទេរឱ្យថ្នាក់ក្រោមជាតិ | ថវិកាគាំទ្រកំណែទម្រង់ស្នូល | | | | | សរុបរួម | ភាគរយ |
|---|---|---|---|---|---|---|---|---|
| | | មូលនិធិកញ្ចប់រួម និងសហភាពអឺរ៉ុប | ថវិកាមានណត់គោលដៅប្រើប្រាស់ | បដិភាគពុំមែនថវិកា | សរុប | ភាគរយ | | |
| **1. ថវិការាជរដ្ឋាភិបាល** | **397,196,250** | **0** | **200,000** | **0** | **200,000** | **0.66%** | **397,396,250** | **90.61%** |
| **2. ថវិកាកម្ចី** | **7,458,803** | **0** | **9,177,701** | **0** | **9,177,701** | **30.45%** | **16,636,504** | **3.79%** |
| 2.1. ADB/DPSFM II | 4,000,000 | 0 | 970,000 | 0 | **970,000** | **3.22%** | **4,970,000** | **1.13%** |
| 2.2. ADB/TS-PRSDP | 717,898 | 0 | 608,534 | 0 | **608,534** | **2.02%** | **1,326,432** | **0.30%** |
| 2.3. ADB/SPCR | 0 | 0 | 630,744 | 0 | **630,744** | **2.09%** | **630,744** | **0.14%** |
| 2.4. ADB/CDRR | 438,000 | 0 | 343,600 | 0 | **343,600** | **1.14%** | **781,600** | **0.18%** |
| 2.5. WB/LASED II | 2,302,905 | 0 | 6,624,823 | 0 | **6,624,823** | **21.98%** | **8,927,728** | **2.04%** |
| **3. មូលនិធិពីដៃគូអភិវឌ្ឍន៍** | **3,801,248** | **11,347,966** | **4,294,004** | **5,117,131** | **20,759,100** | **68.88%** | **24,560,348** | **5.60%** |
| 3.1. Sweden/Sida | 0 | 3,797,156 | 0 | 0 | **3,797,156** | **12.60%** | **3,797,156** | **0.87%** |
| 3.2. EU | 2,000,000 | 5,700,000 | 0 | 0 | **5,700,000** | **18.91%** | **7,700,000** | **1.76%** |
| 3.3. Swiss/SDC | 514,255 | 1,850,810 | 0 | 0 | **1,850,810** | **6.14%** | **2,365,065** | **0.54%** |
| 3.4. ADB/PPTA | 0 | 0 | 0 | 400,000 | **400,000** | **1.33%** | **400,000** | **0.09%** |
| 3.5. GIZ/DAR | 0 | 0 | 0 | 820,000 | **820,000** | **2.72%** | **820,000** | **0.19%** |
| 3.6. IFAD/ASPIRE | 800,000 | 0 | 783,040 | 0 | **783,040** | **2.60%** | **1,583,040** | **0.36%** |
| 3.7. UNCDF/LGCC2 | 430,545 | 0 | 166,363 | 0 | **166,363** | **0.55%** | **596,908** | **0.14%** |
| 3.8. UNDP-EU/ACES | 0 | 0 | 903,223 | 0 | **903,223** | **3.00%** | **903,223** | **0.21%** |
| 3.9. UNFPA | 0 | 0 | 150,000 | 0 | **150,000** | **0.50%** | **150,000** | **0.03%** |
| 3.10. UNICEF/Seth Koma | 56,448 | 0 | 845,880 | 897,131 | **1,743,011** | **5.78%** | **1,799,459** | **0.41%** |
| 3.11. WFP | 0 | 0 | 37,915 | 0 | **37,915** | **0.13%** | **37,915** | **0.01%** |
| 3.12. WB/PFM | 0 | 0 | 685,000 | 0 | **685,000** | **2.27%** | **685,000** | **0.16%** |
| 3.13. Sida/PACT | 0 | 0 | 722,583 | 0 | **722,583** | **2.40%** | **722,583** | **0.16%** |
| 3.14. Demand Side-Social Accountability | 0 | 0 | 0 | 3,000,000 | **3,000,000** | **9.95%** | **3,000,000** | **0.68%** |
| **4. សរុបរួម (1+2+3)** | **408,456,301** | **11,347,966** | **13,671,704** | **5,117,131** | **30,136,801** | **100.00%** | **438,593,102** | **100.00%** |
| **ភាគរយ** | 93.13% | 2.59% | 3.12% | 1.17% | 6.87% | 0.00% | 100.00% | |

## II. សមិទ្ធផលរំពឹងទុកនានានៃ ផ.ស.ថ. ២០១៧

ផ្នែកទី២នេះ គឺជាផ្នែកមួយដ៏សំខាន់នៃឯកសារ ផ.ស.ថ ឆ្នាំ២០១៧ ដែលរៀបរាប់អំពីសមិទ្ធផលរំពឹងទុកទាំង៥របស់ផអ៣ទី២ និងលទ្ធផលរំពឹងទុកនានាក្នុងសមិទ្ធផលរំពឹងទុកនីមួយៗ ដែលត្រូវសម្រេចក្នុងឆ្នាំ២០១៧។ សមិទ្ធផលរំពឹងទុកទាំង៥រួមមាន ៖

១. ការគ្រប់គ្រងការងារកំណែទម្រង់

២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

៤. ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. វិមជ្ឈការហិរញ្ញវត្ថុ

ជាទូទៅ ក្នុងសមិទ្ធផលរំពឹងទុកនីមួយៗមានបរិយាយអំពីសេចក្តីផ្តើម និងចំណុចដៅតាមឆ្នាំនីមួយៗ និងលទ្ធផលរំពឹងទុក។ ដោយឡែក ក្នុងលទ្ធផលរំពឹងទុកនីមួយៗមានរៀបរាប់ដោយសង្ខេបអំពីយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកទាំងនោះ។



ខ្ញ

## ១. សមិទ្ធផលរំពឹងទុកទីមួយ ÷ ការគ្រប់គ្រងការងារកំណែទម្រង់

### ១.១. សេចក្តីផ្តើម និងចំណុចដៅ

ភាពជោគជ័យនៃផអ៣ដំណាក់កាលទី២ អាស្រ័យលើប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចដំណើរការនានានៃកំណែទម្រង់។ សមិទ្ធផលទី១នេះនឹងដោះស្រាយនូវបញ្ហាប្រឈមជាគន្លឹះមួយចំនួន ដែលបានជួបប្រទះក្នុងផអ៣ដំណាក់កាលទី១ដោយចាប់ផ្តើមពី ៖ ១) ការសម្របសម្រួល ដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងទិដ្ឋភាពនយោបាយនៃកំណែទម្រង់ ២) ការពង្រឹងភាពជាម្ចាស់ ៣) ការលើកកម្ពស់ទំនាក់ទំនង និងតម្លាភាព ៤) ការគ្រប់គ្រងការផ្លាស់ប្តូរ និងលទ្ធផលប្រកបដោយប្រសិទ្ធភាព ៥) ការធ្វើឱ្យប្រសើរឡើងនូវការសិក្សារៀនសូត្រ និងការដកស្រង់ពិសោធន៍ និង៦) ការកែលម្អកិច្ចដំណើរការអភិវឌ្ឍន៍គោលនយោបាយ។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់ ដែលត្រូវសម្រេចឱ្យបាន គឺ**ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសំដៅឈានឆ្ពោះទៅរកការគ្រប់គ្រងដែលធានាឱ្យមានការផ្លាស់ប្តូរ។**

ផែនការចំណាយថវិកាសរុបរបស់សមិទ្ធផលរំពឹងទុកទី១មានចំនួន**២.៨៨៥.២៦១**ដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិកាកញ្ចប់រួម/សហភាពអឺរ៉ុបចំនួន**២.៦៨៥.២៦១**ដុល្លារ និងថវិការដ្ឋាភិបាលមានចំនួន**២០០.០០០**ដុល្លារអាមេរិក។

**តារាងទី៥៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី១**

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. គ.ជ.អ.ប. រៀបចំកិច្ចប្រជុំយ៉ាងតិចចំនួន២លើកក្នុង១ឆ្នាំ | --- | 2 | **2** |
| ២. ចំនួនថវិកាចំណាយសម្រាប់ជំនួយបច្ចេកទេស (គិតជាលានដុល្លា) (*) (PAF) | 5.5 | 5.0 | **4.5** |
| ៣. ចំនួនប្រជាពលរដ្ឋដែលបានទទួលការផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីកំណែទម្រង់ និងការផ្លាស់ប្តូរឥរិយាបថ (គិតជានាក់ក្នុង១ឆ្នាំ) | 100 | 100 | **100** |
| ៤. ចំនួនភាគរយនៃស្ថាប័នអនុវត្តកម្មវិធីដែលពេញចិត្តចំពោះការរៀបចំផែនការសកម្មភាព និងថវិកា ការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុដែលសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. | 50% | 60% | **70%** |
| ៥. ចំនួនក្រសួងដែលបានរៀបចំផ្សព្វផ្សាយព័ត៌មានជាសាធារណៈក្នុងការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ | 50% | 60% | **70%** |
| ៦. ចំនួនភាគរយនៃលទ្ធផលរំពឹងទុកជាអាទិភាព និងចំណុចដៅនៃផអ៣ទី២ ដែលបានសម្រេចតាមពេលវេលាដែលបានកំណត់ | 1 | 2 | **5** |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។ ចំណុចដៅក្នុងឆ្នាំ២០១៥ និង២០១៦ គឺជាទិន្នន័យដើមគ្រាធៀបនឹងលទ្ធផលរំពឹងទុកឆ្នាំ២០១៧។ (*)

សូចនាករក្នុងឯកសារផអ៣ទី២ជាភាសារអង់គ្លេសសម្រាប់ឆ្នាំ២០១៧មានចំនួន៤លានដុល្លារ គឺពុំត្រឹមត្រូវទេ។ សូចនាករដែលត្រឹមត្រូវយកតាមឯកសារផអ៣ទី២ជាភាសាខ្មែរដែលមានចំនួន៤,៥លានដុល្លារ។ ជាគោលដៅ គឺត្រូវកាត់បន្ថយថវិកាចំនួន៥០០.០០០ដុល្លារក្នុងមួយឆ្នាំ។ សូចនាករក្នុង PAF សម្រាប់ឆ្នាំ២០១៧ គឺ ១). រៀបចំកិច្ចប្រជុំ គ.ជ.អ.ប. យ៉ាងតិច២ និង២). ចំណាយជំនួយបច្ចេកទេសក្នុងឆ្នាំ២០១៧មិនឱ្យលើសពី៤,៥លានដុល្លារ។

## ១.២. លទ្ធផលរំពឹងទុក និងថវិកា

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី១ស្តីពីការគ្រប់គ្រងការងារកំណែទម្រង់មានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៨ សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៧ដែលរួមមានដូចខាងក្រោម ៖

*លទ្ធផលរំពឹងទុកទី១ ៖ ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. យ៉ាងហោចចំនួន២លើកក្នុងមួយឆ្នាំ ដើម្បីដឹកនាំ និងសម្របសម្រួលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។*

គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការពិនិត្យ និងការអនុម័តគោលនយោបាយនានា និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏ដូចជាការគ្រប់គ្រង និងការសម្របសម្រួលការអនុវត្តកម្មវិធី។ កន្លងមក ការគ្រប់គ្រងការអនុវត្តកម្មវិធីត្រូវបានអនុវត្តតាមរយៈកិច្ចប្រជុំនានាដើម្បីពិនិត្យមើលពីវឌ្ឍនភាពធៀបនឹងអាទិភាពនានាដែលកំណត់ក្នុង ផ.ស.ថ.។ ជាមួយគ្នានេះដែរ អនុគណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងពង្រឹងការរៀបចំកិច្ចប្រជុំ និងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពជាទៀងទាត់ ដើម្បីដាក់ជូន គ.ជ.អ.ប.។

លទ្ធផលរំពឹងទុកនេះនឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាចំនួន១១.៥០០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី២ ៖ ការរៀបចំ និងការអនុម័តផែនការអនុវត្តរយៈពេលបីឆ្នាំ (២០១៨-២០២០) ដំណាក់កាលទី៣នៃកម្មវិធីជាតិ (ផអ៣ទី៣)។*

ដើម្បីរៀបចំផែនការអនុវត្តរយៈពេលបីឆ្នាំ (២០១៨-២០២០) ដំណាក់កាលទី៣នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវធ្វើការអនុម័តជាមុននូវឯកសារបំពេញបន្ថែមលើកម្មវិធីជាតិដោយ គ.ជ.អ.ប. រួមបញ្ចូលទាំងការពន្យារពេលកម្មវិធីជាតិរយៈពេលមួយឆ្នាំដល់ឆ្នាំ២០២០។ ផ្អែកលើឯកសារនេះ ក្នុងឆ្នាំ២០១៧ លេខាធិការដ្ឋាននឹងសម្របសម្រួលរៀបចំផអ៣ទី៣ តាមរយៈកិច្ចដំណើរការដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនានា និងដោយយកចិត្តដាក់លើអាទិភាពមួយចំនួនដូចជា ការពិនិត្យមើលឡើងវិញអំពីគុណភាព វិធីសាស្ត្រ និងប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាព ការអង្កេតអភិបាលកិច្ចមូលដ្ឋានឆ្នាំ២០១៦ (ទាំងបរិមាណ និងគុណភាព) ការបញ្ចប់សវនកម្មយេនឌ័រឆ្នាំ២០១៦ អនុសាសន៍នានានៃការវាយតម្លៃអន្តរកាលទី២នៃកម្មវិធីជាតិ និងការពិនិត្យមើលឡើងវិញនិងការសិក្សាវាយតម្លៃអំពីតម្រូវការជំនួយបច្ចេកទេសសម្រាប់រយៈពេលវែង (យុទ្ធសាស្ត្រកាត់បន្ថយជំនួយបច្ចេកទេស)។

លទ្ធផលរំពឹងទុកនេះនឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាចំនួន២០០.០០០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៣ ៖ ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។*

ជាបណ្តើរៗក្នុងការអនុវត្តកម្មវិធីជាតិ យើងត្រូវគិតអំពីយុទ្ធសាស្ត្រនានាភាពជាម្ចាស់ និងនិរន្តរភាពនៃការអនុវត្តកម្មវិធីដោយរាជរដ្ឋាភិបាលដូចជា ការទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីដោយថវិការដ្ឋ និងការបន្ស៊ីយន្តការ ប្រព័ន្ធ និងនីតិវិធីនានារបស់ គ.ជ.អ.ប. ទៅក្នុងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីរបស់រាជរដ្ឋាភិបាលជាដើម។ អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១៧ កិច្ចការជាអាទិភាពដែលត្រូវយកចិត្តទុកដាក់រួមមាន ៖

- ការរៀបចំយុទ្ធសាស្ត្ររយៈពេលវែងស្តីពីការកាត់បន្ថយជំនួយបច្ចេកទេស និងការកាត់បន្ថយចំណាយប្រតិបត្តិការ
- ការពិនិត្យមើលជាបណ្តើរៗអំពីលទ្ធភាពនៃសមាហរណកម្មលេខាធិការដ្ឋាន គ.ជ.អ.ប. ទៅក្នុងប្រព័ន្ធថវិការបស់រដ្ឋាភិបាល និងបន្តសម្របសម្រួលនិងពិភាក្សា ដើម្បីស្វែងរកការគាំទ្រថវិការដ្ឋដល់លេខាធិការដ្ឋាន គ.ជ.អ.ប. ចំពោះសកម្មភាពស្នូលនានានៃកំណែទម្រង់
- ការពិនិត្យមើលឡើងវិញ និងការកែសម្រួលរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដើម្បីទទួលខុសត្រូវកម្មវិធី និង
- ការពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ និងការគ្រប់គ្រងហិរញ្ញវត្ថុ និងកម្មវិធី ដើម្បីទទួលយកទំនួលខុសត្រូវជាបណ្តើរៗពីទីប្រឹក្សា។

លទ្ធផលរំពឹងទុកនេះនឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយសហការជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងគ្រោងចំណាយថវិកាអស់ចំនួន២៥.០០០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៤ ៖ ការពង្រឹង និងការអនុវត្តកិច្ចដំណើរការអភិបាលកិច្ចការកសាងផែនការ និងការត្រួតពិនិត្យនិងវាយតម្លៃនៃ ផអ៣។*

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន៖

- ការកែសម្រួល និងការអនុវត្តកិច្ចដំណើរការរៀបចំ ផ.ស.ថ. របស់ គ.ជ.អ.ប.
- ការកែសម្រួលតួនាទី និងភារកិច្ចរបស់ទីប្រឹក្សា ដើម្បីឆ្លើយតបនឹងទំនួលខុសត្រូវនៃ ផ.ស.ថ. ឆ្នាំ២០១៧
- ការរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នអនុវត្តន៍នានានៃផអ៣ទី២
- ការគាំទ្រកិច្ចដំណើរការនៃការអនុវត្តនូវបែបផែនការគាំទ្រថវិកា

- ការរៀបចំ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធីសាស្ត្រនៃការសម្របសម្រួលជាមួយគម្រោង កម្មវិធីនានា ដើម្បីធ្វើសមាហរណកម្មគម្រោង កម្មវិធីទាំងនោះក្នុងផអ៣ទី២
- អនុវត្តការត្រួតពិនិត្យតាមដានរួមបញ្ចូលទាំងការរៀបចំនូវទស្សនកិច្ចសិក្សារួមគ្នានៅមូលដ្ឋានរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយដៃគូអភិវឌ្ឍន៍នានា
- ការរៀបចំតាក់តែង និងការអនុវត្តនូវការវិភាគ និងការវាយតម្លៃកម្មវិធី និង
- ការពិនិត្យមើលឡើងវិញ ការកែសម្រួល និងការផ្សព្វផ្សាយឯកសារបច្ចេកទេសស្តីពីគម្រោងមូលនិធិក្រុង ស្រុក និងគម្រោងមូលនិធិឃុំ សង្កាត់។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន**៥០៣.៩៦៥**ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

***លទ្ធផលរំពឹងទុកទី៥ ៖ ការពង្រឹង និងការអនុវត្តនីតិវិធីគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប.។***

ក្នុងឆ្នាំ២០១៦ អង្គការមូលនិធិអាកាសធាតុសកលបានធ្វើការវាយតម្លៃប្រព័ន្ធ និងនីតិវិធីនានានៃការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងបានរៀបចំជាផែនការសកម្មភាព ដើម្បីកែលម្អនីតិវិធី និងសៀវភៅណែនាំនានាស្តីពីរដ្ឋបាល និងហិរញ្ញវត្ថុ និងការធ្វើសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប.។ ដូច្នេះ ចំណាយមួយភាគធំនៃលទ្ធផលរំពឹងទុកនេះពាក់ព័ន្ធនឹងចំណាយសម្រាប់ជំនួយបច្ចេកទេស និងចំណាយប្រតិបត្តការ។ ក្រៅពីនេះ កិច្ចការជាអាទិភាពផ្សេងទៀតរួមមាន ៖

- ការធ្វើសវនកម្មឯករាជ្យលើការអនុវត្តថវិកានៃ ផ.ស.ថ. ឆ្នាំ២០១៦រួមបញ្ចូលទាំងការសិក្សាវាយតម្លៃការអនុវត្តសវនកម្មផ្ទៃក្នុង កិច្ចលទ្ធកម្ម និងការអនុវត្តអនុសាសន៍នានានៃសវនកម្មឯករាជ្យពីឆ្នាំមុន
- ការតាមដាន និងការគាំទ្រស្ថាប័នអនុវត្តក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០១៧
- ការអភិវឌ្ឍសមត្ថភាព និងការអនុវត្តសវនកម្មផ្ទៃក្នុង និង
- ការគាំទ្រចំណាយប្រតិបត្តិការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងការត្រៀមបម្រុងសម្រាប់សកម្មភាព និងចំណាយប្រតិបត្តិការនានាដែលមិនបានគ្រោងទុក។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាចំនួន**១.៩៩៨.២៦០**ដុល្លារ ដែលក្នុងនោះថវិកាចំនួន១.៧៩៨.២៦០ មានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប និងថវិកាចំនួន២០០.០០០ដុល្លារគាំទ្រដោយរដ្ឋាភិបាល។

***លទ្ធផលរំពឹងទុកទី៦ ៖ ការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។***

សកម្មភាពមួយចំនួននៃលទ្ធផលរំពឹងទុកនេះ គឺជាកិច្ចការអាទិភាពដែលត្រូវអនុវត្តបន្តពីឆ្នាំ

២០១៦ដូចជា ការរៀបចំនូវបណ្តុំព័ត៌មាន (រូបថត និងក្រាហ្វិក) ដែលមានគុណភាពខ្ពស់ និងអនុវត្តកម្មវិធីផ្សព្វផ្សាយតាមបែបប្រពៃណី និងទំនើប ធ្វើឱ្យប្រសើរឡើងនូវគេហទំព័ររបស់ គ.ជ.អ.ប ។ ក្រៅពីនេះ នៅមានកិច្ចការដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៧រួមមាន ៖

- រៀបចំ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុកនៃរដ្ឋបាលខេត្តបាត់ដំបងជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា
- រៀបចំ និងផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសរបស់ គ.ជ.អ.ប. នៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម រៀបចំ និងផលិតឧបករណ៍ទំនាក់ទំនងសំខាន់ៗដូចជា សន្លឹកប័ណ្ណព័ត៌មានខ្លីៗ និមិត្តសញ្ញា និងពាក្យស្លោកខ្លីៗ ប្រតិទិន រូបសញ្ញា គ.ជ.អ.ប. សម្រាប់ធ្វើបទបង្ហាញនានា និងកម្រងសំណួរដែលសួរញឹកញាប់ជាងគេ (FAQs)
- រៀបចំផលិត និងផ្សព្វផ្សាយខិត្តបណ្ណព័ត៌មានលើប្រធានបទចំនួន២ដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈវគ្គបណ្តុះបណ្តាលនានា
- រៀបចំអត្ថបទខ្លីៗចំនួន៤ដើម្បីផ្សព្វផ្សាយតាមការសែតឬទស្សនាវដ្តី
- រៀបចំ ផលិត និងផ្សព្វផ្សាយស្ពតខ្លីៗចំនួន១ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមទូរទស្សន៍ដើម្បីលើកកម្ពស់ចំណេះដឹង និងផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋ
- ការអនុវត្តយុទ្ធសាស្ត្រស្តីពីប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងសង្គម
- គាំទ្រដល់រដ្ឋបាលខេត្តចំនួន៣ក្នុងការរៀបចំ និងផ្សព្វផ្សាយកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមវិទ្យុនៅមូលដ្ឋាននៃខេត្តសាមី
- រៀបចំបណ្ណាល័យ គ.ជ.អ.ប ឱ្យមានធនធានមនុស្សទទួល និងឆ្លើយតបនូវព័ត៌មានស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពីសាធារណជន
- ពង្រឹងកិច្ចសហការជាមួយ UNICEF ដើម្បីអនុវត្តយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងក្នុងឃុំគោលដៅចំនួន៤៥ឃុំ អំពីការផ្តល់សេវាសង្គម។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន**១៣៤.៩៥៦**ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប ។

*លទ្ធផលរំពឹងទុកទី៧ ៖ ការពង្រឹងការសម្របសម្រួល និងការប្រឹក្សាយោបល់ជាប្រចាំរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងកម្មវិធីកំណែទម្រង់នានាអំពីការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។*

ដើម្បីលើកកម្ពស់ភាពជាម្ចាស់ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តពង្រឹងសមត្ថភាពនៃក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន តាមរយៈការរៀបចំកិច្ចប្រជុំពិភាក្សានានា

(ផ្លូវការ និងមិនផ្លូវការ) ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីគោលនយោបាយ និងគោលដៅនានាស្តីពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរួមបញ្ចូលទាំង កិច្ចដំណើរការនៃការផ្ទេរមុខងារ និងការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័ននឹងត្រូវបានជំរុញ និងលើកទឹកចិត្តក្នុងការប្រើប្រាស់ថវិការបស់ខ្លួនដើម្បីអនុវត្តសកម្មភាពនានានៃការផ្ទេរមុខងារ។ ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំទស្សនកិច្ចសិក្សារួមគ្នាជាមួយក្រសួងស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសនៅខេត្ត និងក្រុង ស្រុកគោលដៅដែលទទួលបានការផ្ទេរមុខងារ ដើម្បីតាមដាន និងគាំទ្រការអនុវត្តមុខងារដែលបានផ្ទេរ ការគ្រប់គ្រងធនធានមនុស្ស វិមជ្ឈការហិរញ្ញវត្ថុ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន៤.២២០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប ។

### *លទ្ធផលរំពឹងទុកទី៨ ៖ ការពិនិត្យឡើងវិញ និងការសម្រួលរចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ។*

នៅពេលដែលមុខងារត្រូវបានផ្ទេរពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវធ្វើការពិនិត្យមើលឡើងវិញ និងការកែសម្រួលនូវរចនាសម្ព័ន្ធ សមត្ថភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុកទាំងនោះ។ អាស្រ័យហេតុនេះ ទាមទារឱ្យមានការផ្លាស់ប្តូរនូវទំនាក់ទំនងក្នុងការរាយការណ៍ ការកែសម្រួលល័ក្ខខ័ណ្ឌការងារបុគ្គលិក ក៏ដូចជាការអនុវត្តនូវការអភិវឌ្ឍសមត្ថភាពនានា និងការតាមដានត្រួតពិនិត្យ ដើម្បីធានាថា បុគ្គលិកទាំងអស់យល់ដឹងអំពីមុខងារថ្មីរបស់ខ្លួន។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន៧.៣៦០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម។

## ២. សមិទ្ធផលរំពឹងទុកទីពីរ ៖ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

### ២.១. សេចក្តីផ្តើម និងចំណុចដៅ

ការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយទៅជាស្ថាប័នតំណាងពិតប្រាកដរបស់ប្រជាពលរដ្ឋ និងឆ្លើយតបចំពោះសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គឺជាគោលបំណងចម្បងមួយនៃ ផអ៣ទី២។ សមិទ្ធផលនេះ ផ្តោតលើការកំណត់ទំនាក់ទំនងគណនេយ្យភាពរវាងគណអភិបាលជាមួយក្រុមប្រឹក្សាឱ្យបានកាន់តែច្បាស់ ការពង្រឹងគណនេយ្យភាពសង្គមនិងសកម្មភាពចូលរួមរបស់ប្រជាពលរដ្ឋ ការពង្រឹងនូវការធ្វើអធិការកិច្ចលើការអនុវត្តនិងការធ្វើនីត្យានុកូលភាពលើលិខិតបទដ្ឋាននានា និងការរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធប្រតិបត្តិការនានាដូចជា ប្រព័ន្ធគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យានឹងត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីសម្របសម្រួលក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាស្ថាប័នប្រជាធិបតេយ្យនៅមូលដ្ឋានដែលមានស្វ័យភាព និងមានគណនេយ្យភាព ដោយគណអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងស្តង់ដារនានារបស់ជាតិ។**

ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះមានថវិកាសរុបចំនួន**៤.៨១៥.២៩៣**ដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិកាកញ្ចប់រួម/សហភាពអឺរ៉ុបចំនួន៧៨០.៩៦០ដុល្លារ និងថវិការបស់គម្រោង កម្មវិធីនានាមានចំនួន៤.០៣៤.៣៣៣ដុល្លារហើយមួយភាគធំនៃថវិកានេះ គឺជាការចូលរួមចំណែកពុំមែនជាថវិកាពីអង្គការសង្គមស៊ីវិលនានាសម្រាប់ការងារគណេនេយ្យភាពសង្គមផ្នែកតម្រូវការ។

**តារាងទី៦៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី២**

| **សូចនាករ និងចំណុចដៅ** | **2015** | **2016** | **2017** |
|---|---|---|---|
| ១. ក្របខ័ណ្ឌគតិយុត្តត្រូវបានពង្រឹងដើម្បីធានាឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ពិសេសមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធាន និងមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន | អនុវត្ត | អនុវត្ត | អនុវត្ត |
| ២. ចំនួនក្រុង ស្រុកបានអនុម័ត និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុង (*) | 50 | 185 | **185** |
| ៣. ៨០%នៃក្រុមប្រឹក្សាក្រុង ស្រុកយល់ឃើញថាសិទ្ធិអំណាចរបស់ខ្លួនជាមួយគណៈអភិបាលមានភាពរឹងមាំជាងពីមុន | 20% | 50% | **80%** |



ចV

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ៤. ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកប្រើប្រាស់ព័ត៌មាន ទទួលបានតាមរយៈប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ប្រព័ន្ធគ្រប់គ្រងតាមព័ត៌មានវិទ្យា | 100 | 300 | **591** |
| ៥. ចំនួនស្រុកដែលគ្រប់ឃុំទាំងអស់បានបិទបង្ហាញព័ត៌មានដល់សាធារណជន (ស្របតាមការណែនាំស្តីពីការបើកចំហរព័ត៌មាន) បានចូលរួមការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងបានរៀបចំផែនការសកម្មភាពគណនេយ្យភាពរួមគ្នា ដើម្បីកែលម្អការផ្តល់សេវា (*) | 20 | 70 | **120** |
| ៦. កម្មវិធីគណនេយ្យភាពសង្គមដំណាក់កាលទី២ ត្រូវបានរៀបចំដើម្បីបញ្ចូលនូវសេវាផ្សេងៗទៀត និងអនុវត្តនៅថ្នាក់រដ្ឋបាលដទៃទៀត។ | គ្មាន | គ្មាន | អនុវត្ត |
| ៧. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់ | 0 | 1,000 | **3,000** |
| ៨. ចំនួនបណ្តឹងតវ៉ាដែលប្រមូលបាន និងដោះស្រាយដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 0 | 500 | **1,200** |
| ៩. ចំនួនប្រជាពលរដ្ឋចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 5,000 | 7,000 | **9,000** |
| ១០. ចំនួនអង្គការសង្គមស៊ីវិលចូលរួមក្នុងវេទិកាថ្នាក់ស្រុក | 500 | 700 | **900** |
| ១១. ការចូលរួមបដិភាគជាថវិការបស់ឃុំទៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា(គិតជាលានដុល្លារ) | 0.10 | 0.25 | **0.50** |
| ១២. ការវាយតម្លៃពីផលប៉ះពាល់ត្រូវបានបញ្ចប់ដោយប្រៀបធៀបក្រុមប្រជាពលរដ្ឋទទួលផល និងក្រុមប្រជាពលរដ្ឋផ្សេងទៀត ព្រមទាំងបង្ហាញពីការកែលម្អនូវសូចនាករនៃផ្ទាំងព័ត៌មាន | គ្មាន | គ្មាន | អនុវត្ត |
| ១៣. ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលត្រូវបានធ្វើអធិការកិច្ចលើការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងបានទទួលនូវការពេញចិត្តតាមរយៈការវាយតម្លៃ (*) | 20% | 30% | **40%** |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ។ ចំណុចដៅក្នុងឆ្នាំ២០១៥ និង២០១៦ គឺជាទិន្នន័យដើមគ្រាធៀបនឹងលទ្ធផលរំពឹងទុកឆ្នាំ២០១៧។ (*) ចំណុចដៅដូចគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សូចនាករក្នុង PAF សម្រាប់ឆ្នាំ២០១៧ គឺ ១). យ៉ាងតិច ៨០%នៃឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាពគោលដៅក្នុងក្រុង ស្រុកចំនួន៩០បានបញ្ចូលទិន្នន័យ I4C ក្នុងប្រព័ន្ធកុំព្យូទ័រ និង ២). ឯកសារគោលនយោបាយ/ ឯកសារទស្សនទានស្តីពីអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត។

### ២.២. លទ្ធផលរំពឹងទុក និងថវិកា

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី២ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យមានលទ្ធផលរំពឹងទុកចំនួន៤ ហើយលទ្ធផលទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៦ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ដែលរួមមានដូចខាងក្រោម ៖

*លទ្ធផលរំពឹងទុកទី១ ៖ ការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានានៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ខ្សែគណនេយ្យភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

គិតត្រឹមចុងឆ្នាំ២០១៦ រដ្ឋបាលក្រុង ស្រុកទាំងអស់បានអនុម័តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន ហើយបាន និងកំពុងអនុវត្តយ៉ាងពេញលេញនូវប្រព័ន្ធគ្រប់គ្រង និងរដ្ឋបាលដែលបានកំណត់។ ក្នុងឆ្នាំ២០១៧ ដើម្បីពង្រឹងការអនុវត្តនូវមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងសម្របសម្រួលរៀបចំ និងផ្សព្វផ្សាយឯកសារបច្ចេកទេសចំនួន២ដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងបុគ្គលិកក្រុមប្រឹក្សា និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន៦០.០០០ដុល្លារ ដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី២ ៖ ការអនុវត្តផែនការអនុវត្ត ការងារគណនេយ្យភាពសង្គមក្នុងស្រុកគោលដៅចំនួន៩០។*

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៧រួមមាន ៖

- រៀបចំបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការងារគណនេយ្យភាពសង្គម (ផ្នែកតម្រូវការ)
- ជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តុះបណ្តាលដើម្បីឱ្យក្លាយទៅជាប្រតិបត្តិករការងារគណនេយ្យភាពសង្គម(ផ្នែកតម្រូវការ)
- បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត និងរដ្ឋបាលស្រុកដើម្បីលើកកម្ពស់ការយល់ដឹងអំពីការងារគណនេយ្យភាពសង្គម (ផ្នែកផ្គត់ផ្គង់)
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តស្តីពីការងារគណនេយ្យភាពសង្គម
- បណ្តុះបណ្តាលបន្តដល់មន្ត្រីនៃអង្គភាពផ្តល់សេវានៅរដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាពអំពីការងារគណនេយ្យភាពសង្គម
- ប្រមូល បញ្ចូលទិន្នន័យ និងបិទផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋ
- តាមដាន ត្រួតពិនិត្យព័ត៌មានរបស់ប្រជាពលរដ្ឋ និងរៀបចំប័ណ្ណដាក់ពិន្ទុ (ផ្នែកតម្រូវការ)
- រៀបចំកិច្ចប្រជុំរួមរវាងអង្គភាពផ្តល់សេវាទាំងបីជាមួយតំណាងប្រជាពលរដ្ឋ និងសម្របសម្រួលការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ (ផ្នែកតម្រូវការ)
- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ស្រុកស្តីពីដំណើរការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម រៀបចំកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

- ➢ សិក្សា និងបង្ហាញអំពីនិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមដល់អ្នកពាក់ព័ន្ធនានា (អនុវត្តតាមរយៈសមាសភាគទី៤នៃផែនការអនុវត្តគណនេយ្យភាពសង្គម) និងការប្រមូលទិន្នន័យដើមគ្រា។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលក្រុង ស្រុកគោលដៅ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត និងគ្រោងចំណាយថវិកាអស់ចំនួន ៤.៥៤១.០៨៣ដុល្លារ ដែលក្នុងនោះថវិកាចំនួន១៨.៥០០ដុល្លារមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប អង្គការសង្គមស៊ីវិលគាំទ្រចំនួន៣.០០០.០០០ដុល្លារ គម្រោង GiZ/DAR គាំទ្រចំនួន ២៧៣.០០០ដុល្លារ និងអង្គការផេក Sida/PACT គាំទ្រចំនួន៧២២.៥៨៣ដុល្លារ។

*លទ្ធផលរំពឹងទុកទី៣ ៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។*

ផែនការអនុវត្តរយៈពេលបីឆ្នាំនៃកម្មវិធីមានគោលបំណងពង្រីកការទទួលបាន និងការប្រើប្រាស់ឱ្យបានកាន់តែទូលំទូលាយនូវកិច្ចដំណើរការនានានៃការសម្រុះសម្រួលដោះស្រាយបណ្តឹង។ អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១៧ ត្រូវរៀបចំបញ្ចប់នូវអនុក្រឹត្យ និងសេចក្តីណែនាំនានាស្តីពីការបង្កើត និងការប្រព្រឹត្តទៅរបស់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ត្រូវរៀបចំសេចក្តីណែនាំ និងនីតិវិធីនានាសម្រាប់ការស៊ើបអង្កេត និងការសម្រុះសម្រួលដោះស្រាយបណ្តឹង។ ការរៀបចំនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំទាំងនេះក្នុងគោលបំណងលើកកម្ពស់មធ្យោបាយផ្សេងៗ និងការដាក់បណ្តឹងដោយប្រជាពលរដ្ឋឱ្យកាន់តែមានភាពងាយស្រួល ក៏ដូចជាការបង្កើននូវការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្តល់មតិយោបល់ និងដាក់បណ្តឹងនានា (សូមមើលតារាងទី៦)។ បន្ទាប់មក ប្រព័ន្ធនេះនឹងត្រូវធ្វើការផ្សព្វផ្សាយ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ និងគ្រោងចំណាយថវិកាអស់ចំនួន៤៩.៨៤០ដុល្លារដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៤ ៖ ការរៀបចំ និងអនុម័តឯកសារគោលនយោបាយ/ ឯកសារទស្សនទានស្តីពីអធិការកិច្ចរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។*

កិច្ចការជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៧នេះ គឺការពិនិត្យមើលឡើងវិញ និងការវិភាគនានានូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានាដែលមានស្រាប់ស្តីពីអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់នូវជម្រើសនានា សម្រាប់ថ្នាក់ដឹកនាំពិនិត្យ និងសម្រេចអំពីបែបផែននៃការធ្វើអធិការកិច្ច ដើម្បីធានាថា កិច្ចការនេះត្រូវបានអនុវត្តដោយមានការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធនានា។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ និងគ្រោងចំណាយថវិកាអស់ចំនួន៤៦.៧០០ដុល្លារដែលមានប្រភពមូលនិធិគាំទ្រពីថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៥ ៖ ការពិនិត្យមើលឡើងវិញ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ។*

ក្នុងឆ្នាំ២០១៧ កិច្ចការសំខាន់ៗដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះរួមមាន ការដាក់ឱ្យអនុវត្ត និងការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំរបាយការណ៍បញ្ចប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការពិនិត្យកែសម្រួល និងការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់រួមបញ្ចូលទាំងការបញ្ជ្រាបនូវការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងសៀវភៅណែនាំនេះ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ និងគ្រោងចំណាយថវិកាអស់ចំនួន**៨៨.៥៧០**ដុល្លារ ក្នុងនោះថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុបមានចំនួន៧៦.៨២០ដុល្លារ និងថវិកាកម្មវិធីស្បៀងអាហារពិភពលោកមានចំនួន១១.៧៥០ដុល្លារ។

*លទ្ធផលរំពឹងទុកទី៦ ៖ ការរៀបចំ ការធ្វើសមាហរណកម្ម និងការអនុវត្តនូវប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។*

ប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាប្រព័ន្ធ Online ដែលបានរៀបចំក្នុងគោលបំណង ១) ធ្វើវិមជ្ឈការនូវការប្រមូលទិន្នន័យទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ២) ផ្តល់ភាពបត់បែនក្នុងការកំណត់ប្រភេទទិន្នន័យ និងសូចនាករនានា ៣) ពង្រឹងសមត្ថភាពក្នុងការផលិតរបាយការណ៍ទាន់ពេលវេលា និងងាយយល់ដែលជាមូលដ្ឋានសម្រាប់ការពិភាក្សាក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង ៤) លើកកម្ពស់ការទទួលបានទិន្នន័យដល់សាធារណៈ និងអ្នកពាក់ព័ន្ធនានា។ ក្នុងឆ្នាំ២០១៦ ប្រព័ន្ធព័ត៌មាននេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងក្រុង ស្រុក ខណ្ឌចំនួន៤៧ ហើយក្នុងឆ្នាំ២០១៧នឹងត្រូវពង្រីកការអនុវត្តនៅគ្រប់ក្រុង ស្រុក ខណ្ឌទាំងអស់ដែលមានប្រព័ន្ធអ៊ីនធឺណែតប្រើប្រាស់គ្រប់គ្រាន់។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាអស់ចំនួន**២៩.១០០**ដុល្លារដែលគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប។

## ៣. សមិទ្ធផលរំពឹងទុកទីបី ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

### ៣.១. សេចក្តីផ្តើម និងចំណុចដៅ

ចំនួនបុគ្គលិក សមាសភាព សមត្ថភាពជំនាញនិងឥរិយាបថរបស់បុគ្គលិក ការលើកទឹកចិត្តដល់បុគ្គលិក និងការផ្តល់សិទ្ធិអំណាចសមស្រប ដែលធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងបុគ្គលិកទាំងនេះប្រកបដោយភាពបត់បែន គឺជាកត្តាដ៏សំខាន់ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្នុងសមិទ្ធផលរំពឹងទុកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវស្វ័យភាពកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន (ដូចជា ការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការដាក់វិន័យជាដើម) ហើយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិកទាំងអស់។ ការអភិវឌ្ឍសមត្ថភាពនឹងផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពផ្អែកតាមតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងការផ្តល់សេវានៃការអភិវឌ្ឍសមត្ថភាពតាមវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពនានាក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។**

ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបចំនួន**៧.៩៦៨.១០០**ដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិកាកញ្ចប់រួម/សហភាពអឺរ៉ុបចំនួន៦.៣៩០.៨៧៧ដុល្លារ និងថវិកាគម្រោង កម្មវិធីនានាមានចំនួន១.៥៧៧.២២៣ដុល្លារ។

**តារាងទី៧ ៖ សូចនាករ និងចំណុចដៅនានានៃសមិទ្ធផលរំពឹងទុកទី៣**

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជ្រើសរើស តែងតាំង លើកសរសើរ និងដាក់វិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សា | 100% | 100% | **100%** |
| ២. ចំនួនភាគរយមន្ត្រីថ្នាក់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានវាយតម្លៃអំពីគុណផលការងារ ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងផ្ទាល់ | 50% | 75% | **95%** |
| ៣. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលរាជធានី ខេត្ត ជាស្ត្រី | 8.18% | 12.12% | **16.06%** |
| ៤. ចំនួនភាគរយនៃនាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត ជាស្ត្រី | 8.20% | 12.13% | **16.07%** |
| ៥. ចំនួនភាគរយនៃនាយក នាយករងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាស្ត្រី | 16.23% | 19.15% | **22.08%** |
| ៦. ចំនួនភាគរយនៃប្រធាន អនុប្រធានការិយាល័យ អង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ជាស្ត្រី | 21.03% | 22.36% | **23.68%** |

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ៧. ចំនួនភាគរយនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តដែលបានផ្តល់ការគាំទ្រផ្នែកអភិវឌ្ឍសមត្ថភាពទាំង៥ប្រភេទ | 100% | 100% | **100%** |
| ៨. ចំនួនភាគរយនៃអភិបាល និងប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានទទួលវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចប្រចាំឆ្នាំអំពីការបញ្ជាបយេនឌ័រ | 95% | 95% | **95%** |
| ៩. ចំនួនភាគរយនៃសមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលយល់ឃើញថា វគ្គបណ្តុះបណ្តាលបានរៀបចំគ្រប់គ្រាន់សម្រាប់ការអនុវត្តមុខងាររបស់ខ្លួន | 20% | 50% | **80%** |
| ១០.ចំនួនភាគរយនៃកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលផ្អែកតាមតម្រូវការ | 30% | 40% | **50%** |
| ១១.ចំនួនជាមធ្យមនៃដីកាដែលបានដាក់ចេញដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ | 0.5 | 0.75 | **1** |
| ១២.ចំនួនភាគរយនៃសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានកើនឡើង | 10% | 25% | **50%** |

<u>សម្គាល់</u> ៖ ការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពធៀបនឹងសូចនាករ និងចំណុចដៅទាំងនេះនឹងឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ប្រចាំឆ្នាំ ហើយក៏មានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ផងដែរ។ សូចនាករក្នុង PAF សម្រាប់ឆ្នាំ២០១៧ គឺ ១). ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីសម្រាប់ការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ និងការវាយតម្លៃគុណផលនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និង២). លិខិតបទដ្ឋានស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត។ ប្រភេទទាំង៥នៃការអភិវឌ្ឍសមត្ថភាពដូចមានរៀបរាប់ក្នុងសូចនាករទី៧រួមមាន ៖ ការហ្វឹកហ្វឺននិងការសម្របសម្រួល ទំនាក់ទំនងតាមប្រព័ន្ធ Hotline ការផ្លាស់ប្តូរបទពិសោធន៍និងការសិក្សារៀនសូត្រ ការសម្របសម្រួលការអភិវឌ្ឍស្ថាប័ន និងវគ្គបណ្តុះបណ្តាល។

### ៣.២. លទ្ធផលរំពឹងទុក និងថវិកា

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី៣ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលរំពឹងទុកទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៥ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ ដែលរួមមានដូចខាងក្រោម ៖

*លទ្ធផលរំពឹងទុកទី ១ ៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។*

ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តនៅខែមេសា ឆ្នាំ២០១៦។ ដើម្បីអនុវត្តព្រះរាជក្រឹត្យនេះ ទាមទារឱ្យមានការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តសេចក្តីណែនាំជាច្រើនដែលនឹងរៀបរាប់លម្អិតអំពីបែបបទ និងនីតិវិធីសម្រាប់ការរៀបចំផែនការ ការជ្រើស

រើស ការធ្វើកម្មសិក្សា ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្ទេរ និងការឈប់ពីការងារ ការដាក់វិន័យ ការផ្តល់រង្វាន់លើកទឹកចិត្ត ការអភិវឌ្ឍធនធានធានមនុស្ស ការវាយតម្លៃពីគុណផលបុគ្គលិកផ្អែកលើល័ក្ខខ័ណ្ឌការងារ និងកិច្ចការផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមុខងារសាធារណៈ និងគ្រោងចំណាយថវិកាចំនួន**៣៧៨.៦៨០**ដុល្លារអាមេរិក ដែលក្នុងនោះថវិកាចំនួន១០៤.៦៨០ដុល្លារគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប និងថវិកាចំនួន២៧៤.០០០ដុល្លារគាំទ្រដោយគម្រោង GiZ/DAR។

### *លទ្ធផលរំពឹងទុកទី ២ ៖ ការលើកកម្ពស់ និងការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្ននិងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។*

តាមរយៈលទ្ធផលរំពឹងទុកនេះ ថ្នាក់ដឹកនាំទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវចូលរួមវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីបរិយាប័ន្ន និងសមធម៌សង្គម ហើយផ្អែកលើចំណេះដឹង និងជំនាញដែលទទួលបានពីវគ្គបណ្តុះបណ្តាលទាំងនេះ មានមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចនានា ដើម្បីពង្រឹងសិទ្ធិអំណាចក្រុមជនងាយរងគ្រោះនានា រួមទាំងមានមូលដ្ឋានក្នុងការសិក្សាវាយតម្លៃអំពីប្រសិទ្ធភាពនៃកិច្ចការនេះ។ ក្រៅពីនេះ សកម្មភាពផ្សេងទៀតដែលបានកំណត់ក្នុងលទ្ធផលរំពឹងទុកនេះរួមមាន ១) ការបណ្តុះបណ្តាល និងការសម្របសម្រួល បុគ្គលិកនានាអំពីបរិយាប័ន្ន និងសមធម៌សង្គម ២) ការពង្រឹងកិច្ចដំណើរការរបស់ គ.ក.ស.ក. រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងបណ្តាញសមាជិកក្រុម ប្រឹក្សាជាស្ត្រី ៣) ការអនុម័តយុទ្ធសាស្ត្រស្តីពីការ បង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ ៤) ការរៀបចំកិច្ចប្រជុំរបស់ក្រុមការងារយេនឌ័រ និង ៥) ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តការងារស្តីពីបរិយាប័ន្ន និងសមធម៌សង្គម។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងកិច្ចការនារី និងគ្រោងចំណាយថវិកាចំនួន**៥១៨.០១២**ដុល្លារអាមេរិក ដែលជាថវិកាគាំទ្រដោយថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

### *លទ្ធផលរំពឹងទុកទី៣ ៖ ការលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់ស្ថាប័ន រដ្ឋាភិបាលដែលមានស្រាប់ និងកិច្ចសហការរវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។*

លទ្ធផលរំពឹងទុកនេះគ្របដណ្តប់សកម្មភាពនានានៃការអភិវឌ្ឍសមត្ថភាព ដែលអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត រួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពផ្អែកតម្រូវការ និងការអភិវឌ្ឍសមត្ថភាពផ្អែកផ្គត់ផ្គង់ ការហ្វឹកហ្វឺន ការសម្របសម្រួល ការផ្តល់ព័ត៌មាននានាតាមរយៈសារអេឡិចត្រូនិចជាដើម។ កិច្ចការទាំងនេះគាំទ្រលទ្ធផលរំពឹងទុកទាំងអស់នៃ ផ.ស.ថ.។ កិច្ចដំណើរការនៃការអភិវឌ្ឍសមត្ថភាពនឹងត្រូវអនុវត្ត ស្របតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន រួមបញ្ចូលទាំង

ការសិក្សាវាយតម្លៃស្តីពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពផងដែរ។ ជាពិសេស សកម្មភាពនៃការអភិវឌ្ឍសមត្ថភាពនានា នឹងត្រូវធ្វើការបញ្ជ្រាបបរិយាប័ន្ននិងសមធម៌សង្គម និងផ្តោតលើវិមជ្ឈការនៅថ្នាក់ឃុំសង្កាត់ ការរៀបចំថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រធានបទពាក់ព័ន្ធផ្សេងទៀត។

លទ្ធផលរំពឹងទុកនេះនឹងអនុវត្តដោយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយមានការណែនាំ និងគាំទ្រកិច្ចប្រតិបត្តិការពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប និងគ្រោងចំណាយថវិកាចំនួន៥.៦៦៨.១៥០ដុល្លារអាមេរិក ដែលជាថវិកាគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប។

### *លទ្ធផលរំពឹងទុកទី៤ ៖ ការលើកកម្ពស់សមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។*

កន្លងមក សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការគាំទ្រជាច្រើនពីគម្រោង UNDP-EU/ACES ក្នុងការអភិវឌ្ឍសមត្ថភាពសមាជិករបស់ខ្លួន។ ដោយឡែក កម្មវិធីជអ៣ទី២នឹងបំពេញបន្ថែមការគាំទ្រដល់សមាគម ដោយផ្តោតលើការពង្រឹងកិច្ចដំណើរការ និងកិច្ចប្រតិបត្តិការរបស់សមាគម និងគណកម្មាធិការប្រតិបត្តិរបស់ខ្លួន ព្រមទាំងការអភិវឌ្ឍសមត្ថភាព និងការរៀបចំយុទ្ធសាស្ត្រស្តីពីការតស៊ូមតិរបស់សមាគម។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រោងចំណាយថវិកាចំនួន៩៧៣.២៥៨ដុល្លារអាមេរិក ដែលក្នុងនោះថវិកាចំនួន៧០.០៣៥ដុល្លារគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប និងថវិកាចំនួន៩០៣.២២៣ដុល្លារគាំទ្រដោយគម្រោង UNDP-EU/ACES។

### *លទ្ធផលរំពឹងទុកទី៥ ៖ ការរៀបចំ និងការអនុម័តផែនការអនុវត្តន៍សម្រាប់ការបង្កើត និងការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន។*

ការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន គឺជាកិច្ចការមួយដ៏ធំ និងទាមទារការរៀបចំ និងការអនុវត្តជាដំហានៗ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧ កិច្ចការនេះនឹងត្រូវចាប់ផ្តើមជាមួយនឹងការរៀបចំផែនការអំពីផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ប្រព័ន្ធគ្រប់គ្រង ការរៀបចំកម្មវិធីសិក្សា និងការគ្រប់គ្រងកិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាននេះ។ ជាមួយគ្នានេះដែរ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយរៀបចំយុទ្ធសាស្ត្រ ការសិក្សាពីលទ្ធភាព និងការរៀបចំកម្មវិធីសិក្សារបស់សាលា។ កិច្ចការទាំងនេះនឹងកំណត់ពីវិសាលភាពនៃតួនាទី និងភារកិច្ចរបស់សាលា លិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដែលត្រូវការ និងតម្រូវការផ្សេងទៀតសម្រាប់កិច្ចដំណើររបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ និងគ្រោងចំណាយថវិកាចំនួន៤៣០.០០០ដុល្លារអាមេរិក ដែលក្នុងនោះថវិកាចំនួន៣០.០០០ដុល្លារគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប និងថវិកាចំនួន៤០០.០០០ដុល្លារគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

# ៤. សមិទ្ធផលរំពឹងទុកទីបួន ÷ ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ៤.១. សេចក្តីផ្តើម និងចំណុចដៅ

សមិទ្ធផលរំពឹងទុកនេះ មានគោលបំណងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ការងារនេះពាក់ព័ន្ធនឹងការផ្ទេរមុខងារនានាពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត ការលើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ និងការបង្កើតភាពជាដៃគូក្នុងការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋានតាមរយៈមុខងារជាអាណត្តិទូទៅ មុខងារជាកាតព្វកិច្ច ព្រមទាំងការពង្រឹងការផ្តល់សេវារដ្ឋបាលចាំបាច់នានា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវសម្រេចឱ្យបានគឺ **រដ្ឋបាលថ្នាក់ក្រោមជាតិអាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវា និងអាចបម្រើសេវាសំខាន់ៗនានានៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតបំផុត នឹងប្រជាពលរដ្ឋ។**

ផែនការចំណាយនៃសមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបចំនួន**១៩.៩៦៦.១៤៥**ដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិការបស់រាជរដ្ឋាភិបាលមានចំនួន២.៥០៩.២៥០ដុល្លារ ថវិកាកញ្ចប់រួម/សហភាពអឺរ៉ុបចំនួន១.៥៣៥.៩៨៥ដុល្លារ និងថវិកាពីគម្រោង កម្មវិធីនានាមានចំនួន១៥.៩២០.៩១០ដុល្លារ។

**តារាងទី៨ ៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី៤**

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយនៃថវិកាជាតិបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាលទ្ធផលនៃការផ្ទេរមុខងារ (*) | 0.5% | 1% | **3.6%** |
| ២. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុកនៃក្រសួងក្នុងវិស័យសំខាន់ៗ ចំនួន០២ (ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល) | 0 | 2 | **5** |
| ៣. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលនូវការផ្ទេរមុខងារ និងធនធានពីការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុករបស់ក្រសួង ស្ថាប័នក្នុងវិស័យផ្សេងៗទៀតយ៉ាងតិចចំនួន០៣ | 5 | 50 | **185** |
| ៤. ចំនួនរដ្ឋបាលក្រុង ស្រុកដែលបានទទួលការផ្ទេរមុខងារ និងធនធានពាក់ព័ន្ធនឹងសេវាទីប្រជុំជនពីរដ្ឋបាលខេត្ត | 0 | 3 | **10** |
| ៥. ការវាយតម្លៃដោយឯករាជ្យមួយនឹងបង្ហាញឱ្យឃើញថា ការផ្តល់សេវាកាន់តែមានភាពល្អប្រសើរឡើង នៅពេលមុខងារត្រូវបានធ្វើវិមជ្ឈការពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង | --- | --- | **YES** |
| ៦. ចំនួនភាគរយនៃការកើនឡើងនៃការចំណាយពីមូលនិធិឃុំ សង្កាត់ទៅ | 50% | 150% | **300%** |

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| លើសេវាសង្គម | | | |
| ៧. ចំនួនសេវាថ្មី(មិនធ្លាប់អនុវត្តពីមុន)ដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុងស្រុកបានផ្តួចផ្តើម គំនិត និងសាកល្បងក្នុងការផ្តល់សេវា ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក | 2 | 10 | **25** |
| ៨. ចំនួនករណីនៃបទពិសោធន៍ល្អៗអំពីភាពជោគជ័យនៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានប្រមូលចងក្រងជាឯកសារ | 2 | 10 | **50** |
| ៩. ចំនួនថវិកាដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តនូវការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងវិស័យឯកជន សម្រាប់កម្រិតថ្នាក់រដ្ឋបាលនីមួយៗ (គិតជាលានដុល្លារ) | 0.5 | 3 | **9** |
| ១០. ចំនួនភាគរយនៃប្រជាពលរដ្ឋដែលពេញចិត្តចំពោះការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដែលជាគំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 50% | 50% | **50%** |
| ១១. ចំនួនថ្មីបន្ថែមនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ | 6 | 12 | **18** |
| ១២. ចំនួនភាគរយនៃការកើនឡើងនូវសេវារដ្ឋបាលផ្សេងៗដែលផ្តល់តាមរយៈ ការិយាល័យច្រកចេញចូលតែមួយ | 5% | 10% | **15%** |

<u>សម្គាល់</u> ៖ ចំណុចដៅក្នុងឆ្នាំ២០១៥ និង២០១៦ គឺជាទិន្នន័យដើមគ្រាជៀបនឹងលទ្ធផលរំពឹងទុកឆ្នាំ២០១៧។ (*) ចំណុចដៅដូចគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សូចនាករក្នុង PAF សម្រាប់ឆ្នាំ២០១៧ គឺ ១). យ៉ាងហោចក្រុង ស្រុកទាំងអស់ក្នុងខេត្តចំនួន០១ទទួលបានការផ្ទេរមុខងារអប់រំកម្រិតបឋមសិក្សា និង២). ការិយាល័យច្រកចេញចូលតែមួយ និងយន្តការនៃការិយាល័យច្រកចេញចូលតែមួយសរុបមានចំនួន៥២ដែលបានដំណើរការនៅក្នុងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។

### ៤.២. លទ្ធផលរំពឹងទុក និងថវិកា

សមិទ្ធផលរំពឹងទុកទី៤នៃជអ៣ទី២ស្តីពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធផលរំពឹងទុកចំនួន៥ ហើយលទ្ធផលរំពឹងទុកទាំងនេះត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន៧ សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ ដែលក្នុងនោះរួមបញ្ចូលលទ្ធផលរំពឹងចំនួន៣ពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារសំខាន់ៗមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ កន្លងមក មានក្រសួង ស្ថាប័នចំនួន១៤ដែលបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការផ្ទេរមុខងារនេះ ហើយក្រសួងមួយចំនួនដូចជា ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡាជាដើម បានឈានដល់ដំណាក់កាលផ្ទេរមុខងារជាក់លាក់ទៅឱ្យរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌគោលដៅ។ ជារួម ក្នុងឆ្នាំ២០១៧ ក្រសួង ស្ថាប័នទាំង១៤នឹងទទួលបាននូវការគាំទ្រជាបន្តពី គ.ជ.អ.ប. ក្នុងការអនុវត្តកិច្ចដំណើរការផ្ទេរមុខងាររបស់ខ្លួន។ ក្រសួង ស្ថាប័នទាំងនោះរួមមាន ៖

1. ក្រសួងអប់រំ យុវជន និងកីឡា

2. ក្រសួងបរិស្ថាន
3. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
4. ក្រសួងសុខាភិបាល
5. ក្រសួងអភិវឌ្ឍន៍ជនបទ
6. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
7. ក្រសួងធនធានទឹក និងឧតុនិយម
8. ក្រសួងពាណិជ្ជកម្ម
9. ក្រសួងទេសចរណ៍
10. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
11. ក្រសួងរ៉ែ និងថាមពល
12. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
13. ក្រសួងសាធារណៈការ និងដឹកជញ្ជូន និង
14. ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់។

លទ្ធផលរំពឹងទុកទាំង៧ក្នុងឆ្នាំ២០១៧ និងសកម្មភាពសំខាន់ៗ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនេះមានបរិយាយដូចខាងក្រោម ៖

*លទ្ធផលរំពឹងទុកទី១ ៖ ការលើកកម្ពស់ការផ្តល់សេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។*

លទ្ធផលរំពឹងទុកនេះរួមបញ្ចូលសកម្មភាពជាក់លាក់ជាច្រើនរបស់គម្រោង និងកម្មវិធីនានាដែល ពាក់ព័ន្ធនឹងការលើកកម្ពស់សេវាសង្គម កិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបន្ស៊ាំទៅនឹងការប្រែប្រួល អាកាសធាតុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់ថវិកាគាំទ្រមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់សម្រាប់អនុវត្តន៍សកម្មភាពទាំងនេះ។ សកម្មភាពក្នុងលទ្ធផលរំពឹងទុកនេះក៏រួមបញ្ចូលផងដែរនូវការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងការគ្រប់គ្រងគម្រោងថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលនានាក្នុងការផ្តល់សេវា។

គម្រោង កម្មវិធីទាំងនោះរួមមាន ៖

- កម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF ៖ ការលើកកម្ពស់ភាពធន់ ការរស់រានមានជីវិតរបស់សហគមន៍ ការការពារនិងអភិវឌ្ឍន៍កុមារនិងទារក ក៏ដូចជាកុមារពិការ
- ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍរបស់ប្រទេសស្វីស ផ្តល់មូលនិធិតាមរយៈថវិកាកញ្ចប់រួម ដើម្បីគាំទ្រមូលនិធិឃុំ សង្កាត់ក្នុងការលើកកម្ពស់សេវាសង្គម
- គម្រោងកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលគាំទ្រការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពបុគ្គលិកថ្នាក់ក្រោមជាតិ និងការសិក្សារៀនសូត្រ និងការចែករំលែកបទពិសោធន៍នានា

- គម្រោងលើកកម្ពស់សិទ្ធិ និងសុខភាពបន្តពូជ គាំទ្រដោយអង្គការ UNFPA
- គម្រោងកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍកសិកម្មខ្នាតតូចតំបន់ជុំវិញបឹងទន្លេសាប
- គម្រោងសេវាកម្មកសិកម្មសម្រាប់ការផ្តួចផ្តើម ភាពធន់ និងការផ្សព្វផ្សាយ គាំទ្រមូលនិធិដោយ IFAD ដើម្បីលើកកម្ពស់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី២ តាមរយៈកិច្ចអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានានៅមូលដ្ឋាន
- គម្រោងអភិបាលកិច្ចមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ គាំទ្រមូលនិធិដោយ Sida និង UNCDF សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គម្រោងគ្រប់គ្រងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ និងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មបែបថ្មី ដែលធន់នឹងការប្រែប្រួលអាកាសធាតុ គាំទ្រមូលនិធិដោយ ADB។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនការចំណាយមានថវិកាសរុបចំនួន**១៦.៣១៨.៣៦៥**ដុល្លារអាមេរិក ដែលក្នុងនោះថវិកាចំនួន៤៤០.១០០ដុល្លារគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប និងថវិកាចំនួន ១៥.៨៧៨.២៦៥ដុល្លារគាំទ្រដោយគម្រោងកម្មវិធីនានា។

*លទ្ធផលរំពឹងទុកទី២ ៖ ការផ្ទេរ និងការអនុវត្តការប្រគល់មុខងារពាក់ព័ន្ធនឹងគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅ ប្រព័ន្ធដោយរដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តចំនួន១យ៉ាងតិច។*

ក្នុងឆ្នាំ២០១៦ អនុក្រឹត្យស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវបានអនុម័ត និងធ្វើផ្សព្វផ្សាយសម្រាប់ការអនុវត្ត។ ដូច្នេះ ក្នុងឆ្នាំ២០១៧ សកម្មភាពជាអាទិភាពដើម្បីអនុវត្តអនុក្រឹត្យនេះរួមមាន ៖

- ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា
- ការអភិវឌ្ឍសមត្ថភាពបុគ្គលិកក្រុង ស្រុកអំពីការគ្រប់គ្រងមុខងារដែលបានផ្ទេរ និងការអភិវឌ្ឍសមត្ថភាពថ្នាក់ខេត្តក្នុងការគាំទ្រ និងធ្វើអធិការកិច្ចការមុខងារដែលបានផ្ទេរ
- ការអនុវត្តមុខងារដែលបានផ្ទេរ (រួមបញ្ចូលទាំងការគ្រប់គ្រងធនធានបែបវិមជ្ឈការ និងការគ្រប់គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ)
- ការគាំទ្រហិរញ្ញវត្ថុដល់ក្រុង ស្រុកក្នុងការអនុវត្តនូវការផ្ទេរមុខងារ និង
- ការតាមដាន និងការសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការផ្ទេរមុខងារដើម្បីលើកកម្ពស់ការបំពេញការងារ និងពង្រីកការអនុវត្តនេះទៅក្រុង ស្រុកផ្សេងទៀត។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា និងគ្រោងចំណាយថវិកាសរុបចំនួន**១៧០.០០០**ដុល្លារអាមេរិក ក្នុងនោះថវិកាចំនួន៧០.០០០ដុល្លារគាំទ្រដោយ

ថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប និងថវិកាចំនួន១០០.០០០ដុល្លារគាំទ្រដោយ UNICEF។

*លទ្ធផលរំពឹងទុកទី៣ ៖ ការរៀបចំ និងការផ្ទេរមុខងារពីក្រសួងចំនួន២ផ្សេងទៀតយ៉ាងតិចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាលជាដើម។ល។*

ក្នុងឆ្នាំ២០១៧ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាលបានសម្រេចចិត្ត និងមានឆន្ទៈយ៉ាងមុតមាំក្នុងការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកគោល។ ថវិកាសម្រាប់គាំទ្រការអនុវត្តសកម្មភាពទាំងនេះរួមបញ្ចូលផងដែរនូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានចំនួនប្រមាណ២,៥លានដុល្លារ។ ជាមួយគ្នានេះដែរ អង្គការ UNICEF នឹងជួយគាំទ្រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងការផ្ទេរ និងការអនុវត្តមុខងារពាក់ព័ន្ធនឹងការលើកកម្ពស់សេវាសង្គមតាមបែបវិមជ្ឈការ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួង ស្ថាប័នមួយចំនួនដែលមានភាពច្បាស់លាស់ក្នុងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៧ និងគ្រោងចំណាយថវិកាសរុបចំនួន**២.៧០៩.០៥០**ដុល្លារអាមេរិក ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន២.៥០៩.២៥០ដុល្លារ ថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុបមានចំនួន១៨០.០០០ដុល្លារ និងថវិការបស់ UNICEF មានចំនួន១៩.៨០០ដុល្លារគាំទ្រដោយ UNICEF។

*លទ្ធផលរំពឹងទុកទី៤ ៖ ការរៀបចំរបាយការណ៍ស្តីពីការវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារ និងលិខិតបទដ្ឋាននានាស្តីពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងចំនួន១០ផ្សេងទៀត។*

ក្រៅពីក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការសម្របសម្រួលអនុវត្តលទ្ធផលរំពឹងទុកទី២ និងលទ្ធផលរំពឹងទុកទី៣ខាងលើ នៅមានការងារជាអាទិភាពផ្សេងទៀតនៃការផ្ទេរមុខងារ ដែលត្រូវបន្តអនុវត្តដោយក្រសួង ស្ថាប័នមួយចំនួនទៀតដូចជា ការរៀបចំបញ្ចប់របាយការណ៍ស្តីពីការវិភាគ និងការពិនិត្យមើលឡើងវិញនូវមុខងារ ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងនានាដែលអនុវត្តកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រោងចំណាយថវិកាសរុបចំនួន**៤៥០.០០០**ដុល្លារអាមេរិកដែលជាការគាំទ្ររបស់ថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៥ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព ដោយសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា។*

នៅពេលមុខងារត្រូវបានផ្ទេរ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌគោលដៅមានតួនាទី និងភារកិច្ចក្នុងការរៀបចំ និងការអនុវត្តមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាព។ សកម្មភាពក្នុងលទ្ធផលរំពឹងទុកនេះរួមបញ្ចូលផងដែរនូវការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានា ដោយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីបែបបទ និងនីតិវិធីសម្រាប់ការផ្ទេរ និងការអនុវត្តមុខងារទាំងនោះ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌគោលដៅ និងគ្រោងចំណាយថវិកាសរុបចំនួន៨៣.៦៨០ ដុល្លារអាមេរិកដែលជាការគាំទ្ររបស់ថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៦ ៖ ការរៀបចំ និងការផ្ទេរមុខងារនានាស្តីពីការគ្រប់គ្រងសេវាទីប្រជុំជនពីខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។*

ក្នុងឆ្នាំ២០១៧ សកម្មភាពសំខាន់ៗក្នុងលទ្ធផលរំពឹងទុកនេះរួមមាន ការរៀបចំ ការដាក់ឱ្យអនុវត្ត និងការផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តនានាដោយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីបែបបទ និងនីតិវិធីសម្រាប់ការផ្ទេរ និងការអនុវត្តមុខងារទាំងនេះ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌគោលដៅ និងគ្រោងចំណាយថវិកាសរុបចំនួន៣៤.០១០ ដុល្លារអាមេរិកដែលជាការគាំទ្ររបស់ថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៧ ៖ ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន៥២។*

គិតត្រឹមចុងឆ្នាំ២០១៦ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋចំនួន៤៦ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ ហើយក្នុងឆ្នាំ២០១៧ គ្រោងនឹងបង្កើតការិយាល័យនេះចំនួន៦បន្ថែមទៀត។ ដូច្នេះ សកម្មភាពក្នុងឆ្នាំ២០១៧រួមបញ្ចូលផងដែរនូវការគាំទ្រកិច្ចដំណើរការរបស់ការិយាល័យច្រកចេញចូលតែមួយដែលមានស្រាប់ និងគ្រោងបង្កើតថ្មី ព្រមទាំងការសិក្សានានាអំពីលទ្ធភាពសម្រាប់ជាមូលដ្ឋានក្នុងការពង្រីក និងការបង្កើតបន្ថែមនូវយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌគោលដៅ និងគ្រោងចំណាយថវិកាសរុបចំនួន២០១.០៤០ដុល្លារអាមេរិកដែលជាការគាំទ្ររបស់ថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

## ៥. សមិទ្ធផលរំពឹងទុកទី៥៖ វិមជ្ឈការហិរញ្ញវត្ថុ

### ៥.១. សេចក្តីផ្តើម និងចំណុចដៅ

ការរៀបចំ និងការអនុវត្តនូវយន្តការនៃការផ្ទេរហិរញ្ញវត្ថុនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានគោលដៅសំខាន់ក្នុងការបង្កើនលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបាននូវធនធានហិរញ្ញវត្ថុកាន់តែច្រើន សម្រាប់កិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនដូចជា ការផ្តល់មូលនិធិតាមរយៈមូលនិធិក្រុង ស្រុក មូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ មូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការសំខាន់ៗ ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ រួមមានការពិនិត្យមើលឡើងវិញនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាត់បន្ថយភាពយឺតយ៉ាវក្នុងការផ្ទេរមូលនិធិ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួនមានលក្ខណៈប្រាកដប្រជា ព្រមទាំងមានគោលដៅច្បាស់លាស់ក្រោមការដឹកនាំ និងត្រួតពិនិត្យមើលដោយក្រុមប្រឹក្សា។

សមិទ្ធផលរំពឹងទុកដ៏សំខាន់ពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុ ដែលត្រូវសម្រេចឱ្យបានគឺ **ធនធានហិរញ្ញវត្ថុ ត្រូវបានគ្រោងរៀបចំ និងចាត់ចែងប្រើប្រាស់បានយ៉ាងល្អប្រសើរ ព្រមទាំងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តនូវមុខងារអាណត្តិរបស់ខ្លួន។**

ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបប្រមាណ៤០៣លានដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិការបស់រាជរដ្ឋាភិបាលមានចំនួន៣៩៤,៧លានដុល្លារ ថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុបចំនួន២,៤លានដុល្លារ និងថវិកាពីគម្រោង កម្មវិធីនានាមានចំនួន៥,៨លានដុល្លារ។

**តារាងទី៩ ៖ សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលរំពឹងទុកទី៥**

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ១. ចំនួនភាគរយនៃធនធានសម្រាប់សមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តថវិការដ្ឋ | ---- | 0.33% | **0.35%** |
| ២. ចំនួនភាគរយនៃចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក ធៀបនឹងចំណូលសរុបរបស់ខ្លួន (*) | 0% | 2.5% | **10%** |
| ៣. ចំនួនធនធានដែលសហគមន៍មូលដ្ឋានបានចូលរួមសម្រាប់គម្រោងឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក (គិតជាលានដុល្លារអាមេរិក) | 0.2 | 0.5 | **2** |
| ៤. យន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌដើម្បីធានាដល់ការអនុវត្តមុខងារដែលបានផ្ទេរ | ពុំមាន | ពុំមាន | មាន |
| ៥. ចំនួនធនធានដែលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគ (គិតជាលានដុល្លារអាមេរិក) | 0 | 3 | **3** |
| ៦. ចំនួនភាគរយនៃការកាត់បន្ថយនូវភាពយឺតយ៉ាវនៃការផ្ទេរធនធានពីថ្នាក់ | 10% | 25% | **50%** |

| សូចនាករ និងចំណុចដៅ | 2015 | 2016 | 2017 |
|---|---|---|---|
| ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោម (ក្របខណ្ឌពេលវេលា) | | | |
| ៧. ចំនួនភាគរយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានប្រើប្រាស់ប្រព័ន្ធកសាងផែនការថ្មី | 100% | 100% | **100%** |

<u>សម្គាល់</u> ៖ (*) ចំណុចដៅដូចគ្នានឹងផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សូចនាករក្នុង PAF សម្រាប់ឆ្នាំ២០១៧ គឺ ១). បន្ថែមថវិកាចំនួន២លានដុល្លារ ដើម្បីឱ្យសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកឆ្នាំ២០១៧ កើនដល់ចំនួន០,៣៥% ធៀបនឹងចំណូលចរន្តថវិកាជាតិសរុបពីឆ្នាំមុន និង២). ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយរួមបញ្ចូលនូវការវិភាគអំពីការចំណាយសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក និងតាមរយៈការចុះសិក្សាក្នុងក្រុង ស្រុកយ៉ាងតិចចំនួន១០។

## ៥.២. លទ្ធផលរំពឹងទុក និងថវិកា

ផ្អែកតាមផអ៣ទី២ សមិទ្ធផលរំពឹងទុកទី៥ស្តីពីវិមជ្ឈការហិរញ្ញវត្ថុមានលទ្ធផលរំពឹងទុកចំនួន៨ ហើយផ្អែកលើលទ្ធផលទាំងនេះ ត្រូវបានកំណត់ជាលទ្ធផលរំពឹងទុកជាក់លាក់ចំនួន**១១** សម្រាប់ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ ដែលរួមមានដូចខាងក្រោម ៖

*លទ្ធផលរំពឹងទុកទី១ ៖ ការបង្កើនមូលនិធិក្រុង ស្រុកសមាសភាគអភិវឌ្ឍន៍ ដើម្បីបង្កលក្ខណៈឱ្យក្រុង ស្រុកមានធនធានសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន។*

កម្រិត និងនិន្នាការនៃការផ្ទេរមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានរៀបរាប់ក្នុងសេចក្តីផ្តើមនៃផ្នែកទី I។ ក្នុងឆ្នាំ២០១៧នេះ កម្មវិធីផអ៣ទី២នឹងបន្ថែមថវិកាគាំទ្រចំនួន២លានដុល្លារអាមេរិកដល់ផ្នែកអភិវឌ្ឍនៃមូលនិធិក្រុង ស្រុក។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន**៣៩៥.៧៦០.០០០**ដុល្លារអាមេរិក ដែលក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន៣៩៣.៧៦០.០០០ដុល្លារ និងថវិកាចំនួន២.០០០.០០០ដុល្លារគាំទ្ររបស់ថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី២ ៖ ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នាស្តីពីលក្ខខណ្ឌសម្រាប់ការចំណាយមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍។*

ក្នុងឆ្នាំ២០១៧ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ លេខាធិការដ្ឋាននឹងសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យមើលឡើងវិញ និងធ្វើការវិភាគនានា ក៏ដូចជាការចុះបេសកកម្មរួមគ្នា ដើម្បីសិក្សាអំពីបញ្ហាប្រឈមនានា ដែលបានជួបប្រទះកន្លងមកដូចជា ១) ការប្រើប្រាស់ថវិកានៃសមាសភាគអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកសម្រាប់ការប្រើប្រាស់ក្នុងការកែលម្អ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធការិយាល័យក្រុង ស្រុក ជាជាងការផ្តល់សេវា និងការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលជាតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ



១៧

និង ២) មូលនិធិក្រុង ស្រុក ដែលនៅសល់បន្ទាប់ពីការវិភាជសម្រាប់គាំទ្រប្រាក់បៀវត្ស ត្រូវបានកាត់បន្ថយមួយចំនួនទៀតសម្រាប់គាំទ្រចំណាយរដ្ឋបាលទូទៅ។ មូលនិធិដែលនៅសល់ពីការវិភាជទាំងពីរប្រភេទនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់កិច្ចអភិវឌ្ឍន៍។ ក្នុងស្ថានភាពបែបនេះ ចំណាយរដ្ឋបាលទូទៅនឹងត្រូវកើនឡើងជាស្វ័យប្រវត្តិ ហើយទោះបីចំណូលចរន្តនៃថវិកាជាតិមានការកើនឡើងយ៉ាងណាក៏ដោយ ក៏មូលនិធិផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកនៅតែមានកម្រិតទាបដដែល។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាសរុបចំនួន២៦.០០០ដុល្លារអាមេរិក ដែលគាំទ្រដោយថវិកាកញ្ចប់រួមនិងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី៣ ៖ ការដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។*

គិតត្រឹមចុងឆ្នាំ២០១៦ សេចក្តីព្រាងចុងក្រោយនៃអនុក្រឹត្យស្តីពីយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានរៀបចំបញ្ចប់ និងគ្រោងស្នើសុំការអនុម័តនៅដើមឆ្នាំ២០១៧។ ផ្អែកលើអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំសេចក្តីណែនាំ និងនីតិវិធីនានាសម្រាប់ការគ្រប់គ្រង និងការអនុវត្តមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌតាមរយៈការផ្ទេរមុខងារ។ ដូច្នេះ ក្នុងឆ្នាំ២០១៧ នីតិវិធីនេះនឹងត្រូវផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តថវិកានៃមុខងារដែលបានផ្ទេរ។ ជាមួយគ្នានេះដែរ សេចក្តីណែនាំ និងនីតិវិធីនានាដែលមានស្រាប់នឹងត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញរួមបញ្ចូលទាំងការកែសម្រួលរូបមន្តនានាសម្រាប់ការវិភាជមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន២៥០.០០០ដុល្លារអាមេរិក ដែលគាំទ្រដោយ WB/PFM។

*លទ្ធផលរំពឹងទុកទី៤ ៖ ការរៀបចំឯកសារគោលនយោបាយស្តីពីចំណូល និងចំណាយសម្រាប់រយៈពេលវែង និងរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

លទ្ធផលរំពឹងទុកនេះ ត្រូវបានកំណត់ក្នុងគោលបំណងបង្កើនលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ថ្នាក់ក្រោមជាតិទទួលបាននូវធនធានហិរញ្ញវត្ថុកាន់តែច្រើន ដើម្បីលើកកម្ពស់ការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋាន។ អាស្រ័យហេតុនេះ ក្របខ័ណ្ឌគតិយុត្តស្តីពីហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រួមទាំងចំណូល និងចំណាយ) នឹងត្រូវរៀបចំបញ្ចប់ក្នុងឆ្នាំ២០១៧ តាមកិច្ចដំណើរការដែលមានការចូលរួម។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន១៥៥.០០០ដុល្លារអាមេរិក ដែលគាំទ្រដោយ WB/PFM។

*លទ្ធផលរំពឹងទុកទី៥ ៖ ការបន្តការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

បច្ចុប្បន្ន យន្តការចែករំលែកចំណូលពន្ធកំពុងអនុវត្តនៅក្នុងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០១៧ សង្កាត់ដែលស្ថិតនៅក្នុងរាជធានី និងនៅក្នុងក្រុងនឹងទទួលបាននូវចំណូលចែករំលែកបន្ថែមចំនួន៣០%ពីពន្ធលើទ្រព្យសម្បត្តិអចលនវត្ថុ ហើយក្រុង ស្រុកនឹងទទួលបានចំណូលពន្ធចែករំលែកពីរដ្ឋបាលខេត្ត។ ដើម្បីសម្រេចបាននូវកិច្ចការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការវិភាគ និងកំណត់អំពីប្រភពចំណូលនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធនានា និងរៀបចំលិខិតបទដ្ឋាននានាសម្រាប់ការ ប្រមូលចំណូលទាំងនោះ។ ចំពោះការកំណត់ថ្លៃប្រើប្រាស់ និងការចូលរួមបដិភាគរបស់សហគមន៍នឹងត្រូវធ្វើឡើង ដោយមានការប្រឹក្សាយោបល់ជាមួយតំណាងសហគមន៍ និងអង្គការសង្គមស៊ីវិលនានា។ នៅពេលលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំស្តីពីប្រភពចំណូលផ្ទាល់ត្រូវបានអនុម័ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន១៧០.០០០ដុល្លារអាមេរិក ដែលគាំទ្រដោយ WB/PFM។

*លទ្ធផលរំពឹងទុកទី៦ ៖ ការរៀបចំបញ្ចប់ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការអនុវត្តគម្រោងគាំទ្រ ដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ។*

ក្នុងដើមឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំបញ្ចប់សេចក្តីណែនាំ សៀវភៅណែនាំ និងឯកសារពាក់ព័ន្ធនានាស្តីពីការអនុវត្តគម្រោងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា កិច្ចដំណើរនៃការអនុវត្តគម្រោងអាចប្រព្រឹត្តទៅក្នុងឆ្នាំ២០១៧ តាមផែនការគ្រោងទុក។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន២៤៥.០០០ដុល្លារអាមេរិក ដែលគាំទ្រដោយ ADB/DPSFM។

*លទ្ធផលរំពឹងទុកទី៧ ៖ ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។*

ធនាគារអភិវឌ្ឍន៍អាស៊ី បានសន្យាគាំទ្រមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនូវទឹកប្រាក់ចំនួន២០លានដុល្លារអាមេរិក។ ក្នុងឆ្នាំ២០១៧ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- ការសិក្សាវាយតម្លៃអំពីល័ក្ខខ័ណ្ឌអប្បបរមា និងលក្ខណៈសម្បត្តិក្នុងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានសម្រាប់ការវិភាជថវិកាឱ្យរដ្ឋបាលក្រុង ស្រុក
- ការផ្សព្វផ្សាយចំណេះដឹង និងការបណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាអំពីនីតិវិធីនៃមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំ និងការដាក់ស្នើគម្រោងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យវាយតម្លៃគម្រោងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយលេខាធិ

ការដ្ឋានមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការអនុវត្តសាកល្បងនូវគម្រោងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០១៧ មូលនិធិសម្រាប់អនុវត្តគម្រោងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួន៤លានដុល្លារ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន**៥.៦៥២.០០០**ដុល្លារអាមេរិក ដែលក្នុងនោះថវិកាគាំទ្រដោយរាជរដ្ឋាភិបាលមានចំនួន៩២៧.០០០ដុល្លារ និងថវិកាចំនួន៤.៧២៥.០០០ដុល្លារគាំទ្រដោយ ADB/DPSFM។

*លទ្ធផលរំពឹងទុកទី៨ ៖ ការពិនិត្យមើលឡើងវិញ និងការអនុម័តនូវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃថវិការាជធានី ខេត្ត។*

ក្នុងអំឡុងឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការពិនិត្យ និងកែសម្រួលយន្តការ និងរូបមន្តនៃការបែងចែកមូលនិធិសម្រាប់រដ្ឋបាលរាជធានី ខេត្ត តាមរយៈការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធនានា។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រោងចំណាយថវិកាសរុបចំនួន**១១០.០០០**ដុល្លារអាមេរិក ដែលគាំទ្រដោយ ADB/PFM។

*លទ្ធផលរំពឹងទុកទី៩ ៖ ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

ដើម្បីសម្រេចលទ្ធផលរំពឹងទុកនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការសិក្សា និងកំណត់អំពីបញ្ហាប្រឈមនានា តាមរយៈការវិភាគ ការចុះមូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ លទ្ធផលនៃការសិក្សា និងវិភាគនេះនឹងប្រើប្រាស់ជាធាតុចូលក្នុងការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាននានាស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់មក ក្រសួងនឹងរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីនីតិវិធីដែលបានកែសម្រួល រួមបញ្ចូលទាំងការងារគណនេយ្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្ម។ នៅចុងឆ្នាំ២០១៧ ក្រសួងនឹងរៀបចំការពិនិត្យមើលឡើងវិញប្រចាំឆ្នាំអំពីការអនុវត្តនីតិវិធីនេះ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគាំទ្រ និងសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. និងគ្រោងចំណាយថវិកាសរុបចំនួន**១៣៨.៦៩៨**ដុល្លារអាមេរិក ដែលគាំទ្រដោយថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។

*លទ្ធផលរំពឹងទុកទី១០ ៖ ការផ្សព្វផ្សាយ និងការណែនាំសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមប្រភេទថ្នាក់រដ្ឋបាលនីមួយៗ។*

ផ្អែកលើគោលនយោបាយស្ដីពីប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងផែនការ បានពិនិត្យ និងកែសម្រួលសេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមកម្រិត និងប្រភេទរដ្ឋបាលនីមួយៗ។ ក្នុងឆ្នាំ២០១៧ ក្រសួងនឹងផ្សព្វផ្សាយសេចក្ដីណែនាំបច្ចេកទេសនេះដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការពង្រឹងសមត្ថភាពអំពីការប្រមូល និងការផលិតទិន្នន័យ និងព័ត៌មានសម្រាប់ការកសាងផែនការ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងផែនការ និងគ្រោងចំណាយថវិកាសរុបចំនួន**២៦៥.១៤៥**ដុល្លារអាមេរិក ក្នុងនោះថវិកាចំនួន១១៧.៩៨០ដុល្លារគាំទ្រដោយថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប និងថវិកាចំនួន១៤៧.១៦៥ដុល្លារគាំទ្រដោយ UNICEF, UNPFA និង WFP។

*លទ្ធផលរំពឹងទុកទី១១ ៖ ការពង្រឹងការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យមូលដ្ឋាន និងឯកសារពាក់ព័ន្ធ រួមបញ្ចូលទាំងទិន្នន័យអំពីសេវាសង្គម ការប្រែប្រួលអាកាសធាតុសម្រាប់កិច្ចដំណើរការ នៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

ក្នុងលទ្ធផលរំពឹងទុកនេះ រួមមានសកម្មភាពជាអាទិភាពនានាដែលត្រូវអនុវត្តពាក់ព័ន្ធនឹងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រមូល និងការផលិតទិន្នន័យនានាដូចជា ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ តារាងពិន្ទុវិស័យ ទិន្នន័យមូលនៃគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវគ្គរំលឹកឡើងវិញស្ដីពីប្រព័ន្ធទិន្នន័យមូលដ្ឋានទាំងនេះ។

លទ្ធផលរំពឹងទុកនេះ នឹងសម្របសម្រួលអនុវត្តដោយក្រសួងផែនការ និងគ្រោងចំណាយថវិកាសរុបចំនួន១៨៦.៤៦០ដុល្លារអាមេរិកដែលគាំទ្រដោយថវិកាកញ្ចប់រួម និងសហភាពអឺរ៉ុប។